# ការសំភាសន៍របស់ លោកយាយ ឃឹម សយ

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ ឃឹម សយ

## <u>ការសង្ខេបប្រវត្តិរបស់លោកយាយ ឃឹម សយ</u>

អ្នកមីង ឃឹម សយ គាត់មានអាយុ ៦៥ឆ្នាំ ក្នុងឆ្នាំ ២០១៨ អ្នកមីង ឃឹម សយ មានភេទស្រីអ្នកមីង ឃឹម សយ មានទីលំនៅនាពេលបច្ចុប្បន្ន នៅភូមិស្ទឹងជ្រៅ ខេត្តកណ្តាល។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកយាយអំពីពង្សប្រវត្តិតតើលោកយាយអាយអនុញ្ញាត្តិអោយខ្ញុំបាទសំភាសន៍លោកយាយពង្សប្រវត្តិលោកយាយបានដែលរឺទេ???

ខៈ ចាសបាន ៕

កៈ
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍លោកយាយគឺជាថ្ងៃទី០៧ខែ០៤(មេសា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍ឈ្មោះលោកយាយ ឃឹម សយ
ចឹងផ្តើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់លោកយាយបានដែលរឺទេលោកយាយ???

ខៈ ចាសឈ្មោះពេញរបស់ខ្ញុំនឹងមានឈ្មោះ ឃឹម សយ ៕

កៈ បាទហើយសំរាប់លោកយាយមានឈ្មោះហៅក្រៅដែលរឺទេលោកយាយ?

ខៈ ចាសនៅពេលដែលគេហៅក្រៅខ្ញុំនឹងមានឈ្មោះ ឃឹម សយ
នៅក្នុងបញ្ជីជាតិនឹងគេហៅថា ឃឹម វណ្ណី
ចាសហើយនៅពេលដែលគេហៅក្រៅគឺគេហៅលោកយាយ សយ ៕

កៈ
បាទលោកយាយចឹងថាតើលោកយាយមានអាយុប៉ុន្មានឆ្នាំហើយនៅពេលឆ្នាំនឹងដែលលោកយាយ???

ខៈ ចាសសំរាប់ខ្ញុំនឹងឆ្នាំនឹងខ្ញុំមានអាយុ ៦៥ ឆ្នាំហើយចាស៕

ក៖ បាទចឹងឆ្នាំនឹងលោកយាយ មានអាយុ ៦៥ ឆ្នាំហើយហើយសំរាប់លោកយាយមានទីកន្លែងកំណើតនៅទីណាដែទៅលោកយាយ???

ខ៖ ចាសសំរាប់ស្រុកទីកន្លែងកំណើតរបស់ខ្ញុំនឹងមាននៅភូមិប្រសាទឃុំអំពៅព្រៃស្រុកកណ្ដាលស្ទឹងហើយឹងខេត្តកណ្ដាល៕

ក៖ បាទហើយនឹងចឹអរគុណច្រើនលោកយាយហើយចឹងឪពុករបស់លោកយាយមានឈ្មោះអ្វីដែលទៅលោកយាយ???

ខ៖ ចាសសំរាប់ឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះ ប្រុក ជួង ហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះ ឃឹម រឹម ៕

ក៖ បាទហើយសំរាប់លោកទាំង២គាត់មានអាយុប៉ុន្មានឆ្នាំហើយលោកយាយ???

ខ៖ ចាសគាត់ទាំង២គាត់បានស្លាប់តាំងពីជំនាន់ពោលពតមកម្លេះចាសគឺពួកពោលពតនឹងបានយកគាត់យកទៅវៃចោលហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគាត់ទើបតែស្លាប់ជាង១០ឆ្នាំនឹងនោះទេចាស៕

ក៖ បាទហើយចឹងលោកយាយមានបានចាំថាគាត់ទាំង២បានកើតនៅឆ្នាំណាដែលរឺទេលោកយាយ???

ខ៖ ចាសឪពុករបស់ខ្ញុំនឹងគាត់បានកើតយូរដែលហើយហាសចាសហើយសំរាប់គាត់កើតមុនអីសារះទៀតនោះនិយាយយូហើយចាសនិយាយទៅមុខពោលពតទៀតគឺឪពុករបស់ខ្ញុំគាត់៨០ឆ្នាំជាហើយចាសហើយប្រសិនជាគាត់មានជិវិតរស់នៅចឹងហាសគឺគាត់មានអាយុ៨០ឆ្នាំជាងហើយចាសហើយសំរាប់ម្ដាយរបស់ខ្ញុំនឹងគាត់៨០ឆ្នាំជាងហើយចាសនិយាយឪពុករបស់ខ្ញុំនឹងគាត់មានអាយុ ៨៥ឆ្នាំ រឺក៏៨៦ឆ្នាំហើយចាស៕

ក៖ បាទហើយចឹងលោកយាយមានបានដឹងថាគាត់ទាំង២មានទីកន្លែងកំណើតនៅទីកន្លែងណាដែលរឺទេលោកយាយ???

ខ៖ ចាសលោកទាំង២មានទីកន្លែងកំណើតនៅភូមិប្រសាទនឹងតែម្ដងអំពៅព្រៃស្រុកកណ្ដាល

ស្ទឹងហើយនឹងខេត្តកណ្តាលហើយសំរាប់ម្តាយរបស់ខ្ញុំនឹងក៏គាត់មានទីកន្លែងកំណើតអំពៅព្រៃស្រុកកណ្តាលស្ទឹងហើយនឹងខេត្តកណ្តាលដែលតែម្តង៕

ក៖
បាទចឹងបានន័យថាលោកទាំង២មានទីកន្លែងកំណើតនឹងនៅស្រុកជាមួយនឹងគ្នាមែនដែលទេលោកយាយ???

ខ៖ ចាសលោកទាំង២មានទីកន្លែងកំណើតនឹងនៅស្រុកជាមួយនឹងគ្នា៕

ក៖
បាទហើយចឹងអរគុណច្រើនលោកយាយហើយចឹងលោកយាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែលទៅលោកយាយ???

ខ៖ ចាសសព្វថ្ងៃនឹងខ្ញុំនឹងមានបងប្អូនចំនួន ៨នាក់ ចាស៕

ក៖ បាទហើយចឹងលោកយាយចាំឈ្មោះរបស់គាត់ទាំងអស់ដែលរឺទេ???

ខ៖ ចាសចាំ៕

ក៖
បាទចឹងលោកយាយអាចរាប់ឈ្មោះគាត់ទាំង៨នាក់នឹងម្នាក់ម្តងម្នាក់ម្តងបានដែលរឺទេលោកយាយ???

ខ៖ ចាសបាន ទី១ នឹងគឺខ្ញុំនឹងតែម្តងគឺខ្ញុំនឹងមានឈ្មោះថា យឹម សយ ហើយទី២ យឹម ផល្លី ហើយទី៣ យឹម សុខរ៉ាត់ ទី៤ យឹម សុភាព ទី៥ យឹម សុភា ទី៦ យឹម សុធី ទី៧ យឹម សំម្បស់ ហើយនឹងទី៨ យឹម សុផាន់
ចាសហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងគាត់មានជីវិតរស់នៅទាំងអស់ចាស៕

ក៖
បាទហើយចឹងពួកគាត់បានរស់នៅភូមិជាមួយនឹងលោកយាយដែលរឺក៏រស់នៅឆ្ងាយពីលោកយាយ???

ខ៖
ចាសនិយាយទៅមានអ្នកខ្លះគាត់បានរស់នៅភូមិនឹងដែលហើយក៏មានអ្នកខ្លះនឹងគាត់បានទៅរស់នៅស្រុកស្រែកចឹងទៅចាសនិយាយទៅគឺរស់នៅទាំងអស់គ្នា៕

ក៖ បាទពួកគាត់ទាំងអស់នឹងមានអាយុប៉ុន្មានឆ្នាំហើយទៅលោកយាយ???

ខ៖ ចាសមានអ្នកខ្លះនឹងមានអាយុ
៥០ឆ្នាំជាងហើយក៏មានអ្នកខ្លះនឹងមានអាយុ៦០ឆ្នាំជាងចឹងទៅចាសតរតរគ្នាហើយមានអ្នកខ្លះនឹងមានអាយុ៥០ឆ្នាំជាចឹងទៅចាសហើយសំរាប់ខ្ញុំនឹងគឺជាបងគេទាំងអស់នឹងចាស៕

ក៖
បាទចឹងអរគុណច្រើនលោកយាយហើយចឹងខ្ញុំនឹងចង់សួរលោកយាយទៀតថាតើលោកយាយស្វាមីដែលរឺទេលោកយាយ???

ខ៖ ចាសនិយាយទៅគឺខ្ញុំនឹងអត់មានប្ដីនោះទេ៕

ក៖ បាទចឹងលោកយាយអត់មានប្ដីតាំងពីជំនាន់ពោលពតមក???

ខ៖ ចាសនិយាយទៅគឺអត់មាន៕

ក៖ ចឹងលោកយាយនៅក្រមុំចាស់មែនដែលទេលោកយាយ???

ខ៖
ចាសគឺខ្ញុំនឹងនៅក្រមុំចាស់បាទចឹងលោកយាយរាល់ថ្ងៃនឹងថាតៀលោកយាយរស់ជាមួយអ្នកគេដែលទៅលោកយាយ???

ខ៖
ចសាសំរាប់ខ្ញុំនឹងបានសុំកូនគេមួយហើយគេនៅចំការហាសហើយនៅពេលនឹងទៅក៏ខ្ញុំនឹងខំចិញ្ចឹមគេទៅហើយនៅពេលដែលខ្ញុំនឹងបានចិញ្ចឹមនឹងគឺខ្ញុំនឹងបានចៅចំនួន ៣នាក់ហើយនៅពេលដែលគេបានរៀបការអស់ចឹងទៅហើយក៏មានអ្នកខ្លះនឹងបានលេងលះគ្នាទៅហើយនៅពេលដែលគេបានលេងលះគ្នាចឹងខាងប្រុសនឹងក៏គេបានាទៅយកប្រពន្ធមួយទៀតចឹងទៅហើយគេក៏បានទុក្ខចៅចំនួន ៣នាក់អោយខ្ញុំនឹងចិញ្ចឹមគេចឹងទៅចាស៕

ក៖ បាទហើយចឹងចៅរបស់លោកយាយទាំង
៣នាក់នឹងពួកគាត់មានឈ្មោះអ្វីដែលទៅលោកយាយ???

ខ៖ ចាសចៅទាំង៣នាក់របស់ខ្ញុំនឹងគេមានឈ្មោះ ឃឹម ថារជនា ឃឹម រាចិត្រា ហើយនឹង ឃឹម រាសិលា ចាស ៕

ក៖
បាទហើយចឹងអរគុណច្រើនលោកយាយហើយចឹងថាតើលោកយាយនៅពីក្មេងនឹងថាតើលោកយាយមានសិក្សាដែលរឺទេលោកយាយ???

ខ៖ ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងបានរៀនសូត្របានថ្នាក់ទី៣
ចាសយើងពីក្មេងអីនឹងគឺយើងនឹងមិនជាសូវបានរៀនសូត្រអីនោះទេចាសទើបតែបានមក

រៀនល្វនឹងដែលបានបែកនឹងគ្រាន់តែបានតិចនឹងចាសហើយខ្ញុំនឹងបានរៀនបានទ្រឹមថ្នាក់ទី ៧ ចា៕

ក៖
បាទហើយលោកយាយបានរៀនបានថ្នាក់ទីនឹងថាតើលោកយាយបានរៀននៅសាលាណាវិញដែលទៅលោកយាយ???

ខ៖
ចាសកាល់នឹងនៅពេលដែលយើងនឹងបានបែកមកសំម្តេចគាត់អោយអ្នកដែលរៀនមិនចេះអក្សរនឹងបានឡើងវិញចឹងហាសពីព្រោះអីនឹងនៅពេលដែលយើងបានទៅរៀននៅសាលាករុកសលនឹងចាសដែលសាលានឹងគឺគេបានហៅថាដូចជាសាលារៀនសម្តេចហ៊ុនសែនចាសដែលទើបតែបង្កើតថ្មីនឹងចាសល្វនឹងគឺគេឈប់ហើយគឺគេបានអោយឈប់អោយយើងបានរៀនចឹងទៅចាសហើយចាប់ពីនឹងទៅគឺគេបានបង្កើតសិស្សថ្មីថ្មីចឹងទៅហើយនៅពេលដែលយើងឃើញចាស់ចឹងទៅគេក៏បានអោយយើងនឹងបានឈប់រៀនចឹងទៅហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងធ្វើការងារបណ្តើលហើយយើងនឹងរៀនបណ្តើលចឹងទៅហាសកាល់នឹងវាពិបាក់ដែលចឹងហាស៕

ក៖
បាទហើយចឹងលោកយាយបានរៀនសូត្របានត្រឹមថ្នាក់ទី៧នឹងគឺនៅសាលាតាខ្មៅនឹងតែម្តងមែនដែលទេលោកយាយ???

ខ៖
ចាសកាល់នឹងគឺខ្ញុំនឹងបានរៀនសូត្របានត្រឹមថ្នាក់ទី៧នឹងគឺនៅសាលាតាខ្មៅនឹងតែម្តងហើយដែលនៅជំនាន់នោះទេគេបានបើកថ្មីចឹងហាសមិនដូចល្វនឹងទេហាសចាសសាលារៀនគេបានចាប់បើកបង្រៀនក្មេងក្មេងត្រឹមជាង២០ហើយពេលនឹងគេអោយទៅធ្វើការងារហើយនឹងបានរៀនសូត្រចឹងទៅហាសចាសដើម្បីអោយគេនឹងបានចេះឡើងវិញហើយអ្នកណាដែលគេមិនបានចេះចឹងគឺគេក៏បានអោយរៀនសូត្រឡើងវិញចឹងហាសនិយាយគឺអោយរៀនបំពេញវិជ្ជាដែលគេហៅថាសាលាបំពេញវិជ្ជាយើងនឹងចាសកាល់នឹងគឺគេបានបង្កើតសាលាបំពេញវិជ្ជាចាសហើយសំរាប់យើងនឹងក៏បានទៅបំពេញនឹងគេចឹងទៅហាសហេហេហេហេ៕

ក៖
បាទអត់អីទេលោកយាយហើយចឹងសំណួរដែលខ្ញុំនឹងចង់លោកយាយបន្ថែមទៀតថាតើរាល់ថ្ងៃនឹងលោកយាយប្របកមុខរបបអ្វីដែលទៅលោកយាយ???

ខ៖
ចាសសំរាប់ខ្ញុំនឹងរាល់ថ្ងៃនឹងគឺខ្ញុំនឹងប្រកបមុខរបបលក់នុំចាសគឺខ្ញុំនឹងលក់តែនុំនោះទេចាស៕

ក៖ បាទសំរាប់លោកយាយលក់នុំអ្វីខ្លះដែលទៅលោកយាយ???

ខ៖ ចាសសំរាប់ខ្ញុំនឹងមានលក់នុំដូចជា នុំកង នុំអន្សោម នុំក្រូច នុំជាច្រើនទៀតចឹងទៅហាសពីព្រោះយើងចេះតែផ្លាស់ប្តូររាល់ថ្ងៃចឹងទៅហាសហេហេហេចាសហើយសំរាប់ថ្ងៃនឹងគឺខ្ញុំនឹងមានលក់នុំកងហើយនឹងនុំក្រូចចឹងទៅហើយនៅពេលដែលថ្ងៃស្អែកទៅយើងនឹងលក់នុំអន្សោមអីចឹងទៅចាសហេហេហេ៕

ក៖
បាទហើយសំរាប់លោកយាយប្រកបមុខរបបនឹងហើយនឹងលក់វារាល់ថ្ងៃរីក៏យ៉ាងមិចដែលទៅលោកយាយ???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងលក់នុំនឹងគឺរាល់ថ្ងៃចឹងទៅហើយពេលណាដែលខ្ញុំនឹងឈឺចឹងទៅគឺខ្ញុំនឹងសំរាក់ចឹងទៅហេហេហេហើយសំរាប់ថ្ងៃណាដែលយើងនឹងមិនឈឺចឹងទៅយើងនឹងក៏បានទៅលក់ទៀតចឹងទៅហាសចាសនឹងខ្ញុំនឹងឈប់២ថ្ងៃហើយហើយខ្ញុំទើបតែថ្ងៃនឹងទេហើយអត់ចឹងនិយាយគឺខ្ញុំនឹងឈឺហើយវារល់អត់ស្រួលហាសចាសហើយដល់ពេលនឹងទៅខ្ញុំនឹងឈប់សំរាក់ហើយខ្ញុំនឹងក៏បានប្រាប់ចៅអីចឹងទៅចាសហើយដល់ពេលដែលខ្ញុំនឹងបានជាហើយចឹងទៅក៏ខ្ញុំនឹងបានទៅទៀតចឹងទៅហេហេហេ៕

ក៖
បាទអរគុណច្រើនលោកយាយហើយចឹងថាតើនៅពេលដែលលោកយាយឈឺចឹងថាតើមានអ្នកណាដែលបានកូសខ្យលអោយលោកយាយទៅ???

ខ៖
ចាសនៅពេលដែលខ្ញុំនឹងឈឺគឺមានតែចៅរបស់ខ្ញុំនោះទេដែលតែតែងកូសខ្យលអោយខ្ញុំចឹងហាសចាសនិយាយទៅបានតែចៅនឹងទេដែលបានកូសខ្យលអោយខ្ញុំនឹងហាសចាស៕

ក៖
បាទហើយចឹងក្រៅពីជំនាន់ដែលលោកយាយនៅពីក្មេងលោកយាយបានរៀនសូត្រត្រឹមថ្នាក់ទី៣ហើយនៅពេលដែលនៅក្នុងជំនាន់សម្តេចមកលោកយាយបានរៀនសូត្រត្រឹមថ្នាក់ទី៧បាទហើយសំរាប់លោកយាយមានចេះអ្វីក្រៅពីភាសាខ្មែរដែលរឺទេលោកយាយ???

ខ៖
ចាសំរាប់ខ្ញុំនឹងអត់ចេះភាសាណាទេក្រៅពីភាសាខ្មែរតែមួយមុខទេនិយាយទៅគឺចេះតែខ្មែរនឹងតែម្តងចាសហេហេ៕

ក៖
បាទចឹងអត់អីទេលោកយាយហើយចឹងលោកយាយមានអ្វីដែលលោកយាយចូលចិត្តដែល

រីទេនៅពេលដែលោកយាយនៅសិក្សាណាលោកយាយមានដូចជាការច្រៀនលេងជាមួយនឹងមិត្តភក្តិរីក៏មានមិត្តភក្តិណាដែលសិទ្ធស្នាលជាមួយនឹងលោកយាយដែលរីទេលោកយាយ???

ខ៖
ចាសកាល់នឹងនៅពេលដែលខ្ញុំនឹងមានការងារធ្វើចឹងទៅចេះតែមានការលេងសើចអីចឹងទៅហាសដល់តែពេលដែលយើងនឹងបានបែកគ្នាអស់ចឹងទៅមានក៏មានអ្នកខ្លះនឹងក៏គេបានាស្លាប់អស់ចឹងទៅហើយនៅមានស្រុករស្រុករនឹងខ្ញុំនឹងហាសចាសចុះនៅពេលដែលគេបានរំសាយការងារកន្លែងគេនឹងហើយគេអស់មានការងារអស់ចឹងទៅហើយយើងនឹងក៏បានបែកគ្នាចឹងទៅហើយនៅពេលដែលយើងនឹងនៅពីក្មេងនឹងយើយងចេះតែបានលេងជាមួយនឹងគ្នាចឹងដែលហេហេហេហេហេនិយាយទៅគឺសប្បាយដែលតាសចាស៕

ក៖
បាទសំរាប់កាល់ដែលលោកយាយនៅពីក្មេងនឹងថាតើបទអ្វីដែលដែលោកយាយចូលចិត្តច្រៀងលេងហាសលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងចូលចិត្តបទតែពីដើមចឹងហាសចាសហើយល្មវនឹងដូចជាចង់ភ្លេចហើយចឹងហាសបទដូចជាភ្លេចអស់ហើយល្មវនឹងចាសដូចជាបទសង់ទីម៉ងហេហេហេភ្លេចអស់ហើយចាស៕

ក៖
បាទចឹងើលោកយាយបានភ្លេចហើយបាទអត់អីទេលោកយាយហើយចឹងនៅពេលដែលលោកយាយបានទៅរៀននឹងថាតើមានអ្វីនឹងធ្វើដំណើលទៅសាលារៀនដែលរីលោកយាយ???

ខ៖
ចាសសំរាប់ខ្ញុំនឹងគឺគ្មាននោះទេនិយាយគឺខ្ញុំនឹងមានតែកង់ហើយខ្ញុំនឹងចេះកង់ចាសនិយាយទៅខ្ញុំនឹងមានកង់ហាសចាសកាល់នឹងដូចជាឆ្នាំ ១៩៨៦
ចាសហើយពេលនឹងយើងបានរៀបបំពេញវិជ្ជាហើយពេលនឹងយើងចេះកង់ហើយមិត្តភក្តិរបស់យើងនឹងមានកង់ដែលចាស់ចាស់ចឹងទៅយើងចេះតែជិះចឹងទៅហេហេហេ៕

ក៖
បាទលោកយាយហើយចឹងនៅពេលដែលលោកយាយជិះកង់ពីនឹងទៅទៅសាលារៀននឹងថាតើមានចំនួនប៉ុន្មានគីឡូម៉ែត្រដែលលោកយាយ???

ខ៖
ចាសនិយាយទៅជិតដែលនោះទេចាសពីព្រោះអីនឹងកាល់នឹងគឺខ្ញុំនឹងបានធ្វើការងារនៅទី

ន្លែងខាងឧស្សាហ៍កម្មនឹងហាសចាសនិយាយទៅគឺដីចំនួន១គីឡូដីដី១គីឡូចាសតែសំរាប់នៅពេលដែលយើងនឹងចេញពីផ្ទះនឹងគឺ២គីឡូគឺ២គីឡូជាងអីនឹងចាស៕

កៈ
បាទហើយសំរាប់ការជិះពីផ្ទះរបស់លោកយាយទៅសាលារៀននឹងគឺ២គីឡូថាតើលោកយាយប្រើពេលរយះពេលប៉ុន្មានម៉ោងដែលទៅលោកយាយ???

ខៈ
ចាសសំរាប់គឺ២គីឡូដីយើងជិះមិនបានកន្លះម៉ោងនោះទេចាសពីព្រោះអីកាល់នៅក្នុងជំនាន់នឹងគឺគេមិនជាសូវមានឡានអីចឹងហាសចាសហើយក៏វាមិនដូចជាល្វូវនឹងដែលចាសកង់មួយមួយហើយនឹងម៉ូតូមួយមួយចាសគឺមិនដូចជាល្វូវនឹងនោះទេចាសហើយសំរាប់ល្វូវនឹងគឺវាទំនើបហើយនឹងពេញតែម្តងហាសចាសហេហេហេចាសពីព្រោះអីនឹងគឺសម័យនឹងគឺជាសម័យជើនលឿនចឹងទៅគឺវាណែនប៉ែសចាសនិយាយទៅសំបូរបែបចឹងហោះហេហេហេ៕

កៈ
បាទនឹងហើយលោកយាយចឹងលោកយាយជិតតែកន្លះម៉ោងអីនឹងគឺដល់ហើយមែនដែលទេលោកយាយ???

ខៈ
ចាសជិតតែកន្លះម៉ោងអីនឹងគឺដល់ហើយហេហេហេចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងជិះលឿនដែលពីព្រោះអីគឺវាវាល់ដែលចឹងហាសអូនហើយផ្លូវវាវាល់ហោះចាសហើយពេលសម័យនឹងក៏វាគ្មានឡានហើយនឹងម៉ូតូដូចល្វូវនឹងដែលទេចាសនិយាយទៅគឺមានតែមួយមួយនឹងចាសហើយសំរាប់ឡាននឹងក៏មានតែមួយមួយដែលហាសតែសំរាប់ល្វូវនឹងគឺវាណែនប៉ែសគឺគ្រាប់តែគ្នាចឹងហាសហេហេហេហើយវាមានជាជួរហើយនឹងគឺវាណែនប៉ែសហើយដំពេលដែលស្រុករបស់យើងនឹងបានជើនលឿនចឹងទៅ៕

កៈ
បាទហើយចឹងខ្ញុំនឹងចង់សួរលោកយាយបន្ថែមទៀមថាតើនៅពេលដែលោកយាយបានរៀននៅថ្នាក់ទី៣នឹងថាតើលោកយាយគឺជាសិស្សពូកែរឺក៏ជាសិស្សមធ្យមរឺក៏ជាសិស្សខ្សោយរឺក៏យ៉ាងមិចដែលទៅលោកយាយ???

ខៈ
ចាសសំរាប់ខ្ញុំនឹងគឺជាសិស្សមធ្យមចាសសំរាប់កាល់នឹងគឺខ្ញុំនឹងរៀនបានមធ្យមនោះទេចាស៕

កៈ
បាទហើយចឹងនៅពេលដែលលោកយាយបានរៀនហើយនឹងជាសិស្សមធ្យមនឹងថាតើលោ

កយាយបានរៀនបានអ្វីខ្លះទៅលោកយាយបាទដូចជាភាសាខ្មែរហើយនឹងសិក្សាសង្គមហើយនឹងវិទ្យាសាស្ត្រចឹងហាសលោកយាយ???

ខ៖
ចាសកាល់នឹងខ្ញុំនឹងមករៀនដូចជាខានចឹងហាសនិយាយគឺខ្ញុំនឹងសិស្សមធ្យមខាងអក្សរខ្មែររបស់យើងនឹងហាសចាសគឺមធ្យមខាងអក្សរខ្មែរចាសហើយសំរាប់កាល់នឹងដូចជាសៀវភៅសាម៉ាស្វានចាសគឺពីដើមហាសហើយសំរាប់ក្មេងនឹងគឺមិនដូចជាស្វស្គាល់នោះទេចាសពីដើមសៀវភៅសាម៉ាស្វានចាសហើយរៀនកាល់នឹងដូចជាបូណាចាំចំការហើយនឹងបំបែកកកាអីចឹងទៅហាសនឹងហើយគឺយើងរៀនឡើងបានចឹងមកហាសហេហេហេ៕

ក៖ បាទហើយអានឹងគឺមិនមែនជាសៀវភៅធម្មអីណាលោកយាយ???

ខ៖
ចាសនឹងគឺមិនមែនជាសៀវភៅធម្មនោះទេចាសកាល់ដែលខ្ញុំនឹងបានរៀនគឺជាសៀវភៅសាម៉ាស្វានកខហើយមកកការហើយយើងសរសេរអក្សរដូចជាសំចាំចំការចឹងហាសចាសហើយមិនដូចជាលូវនឹងនោះទេចាសកាល់ពីដើមនឹងគឺគេដែលបានរៀនដំណើលខ្ញុំនឹងហេហេហេ កកាកិកី៕

ក៖
បាទចឹងលោកយាយពូកែខាងភាសាខ្មែរមែនដែលទេលោកយាយបាទហើយចឹងនៅក្នុងជំនាន់ថាតើលោកយាយរៀនបានជាប់ចំណាប់ថ្នាក់លេខប៉ុន្មានដែលទៅលោកយាយ???

ខ៖
ចាសសំរាប់ជំនាន់នឹងខ្ញុំនឹងដូចជាអត់ស្វរដឹងដែលទេអូននិយាយទៅដូចថាយើងរៀនបានតាមធម្មតាហើយនឹងនឹងយើងរៀនបានមធ្យមមធ្យមចឹងហាសចាសហើយយើងរៀនមិនបានខ្លាំងនោះទេពីព្រោះអីយើងនឹងនៅតែស្រែចឹងហាសចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងថាតើថ្នាក់ទីប៉ុន្មានដែលគេគេនិយាយថ្នាក់ដែលធំជាងហាសលោកយាយដែលនៅក្នុងជំនាន់នឹងថ្នាក់ទីប៉ុន្មានដែលទៅលោកយាយ???

ខ៖
ចាសនិយាយទៅគឺគ្មានថ្នាក់ទីប៉ុន្មានទេអូនចាសកាល់នឹងចាសហើយសំរាប់ប្អូនរបស់ខ្ញុំនឹងគឺវាបានរៀនបានថ្នាក់ទីប៉ារ៉េកទីយ៉ាងមិចរបស់គេទេហើយខ្ញុំនឹងដូចជាមិនជាស្វរជាចេះនោះទេហាសចាសកាល់ពីដើមហើយលូវនឹងយើងបានមានភាពដែលគេហៅថាវ៉ៃចំណាស់ចឹងហាសហើយនឹងក៏មិនជាស្វរមានការចង់ចាំដែលចឹងហាសចាសក្មេងក្មេងចាសហើយសំរាប់ពីដើមគេមានថ្នាក់អ្វីដូចយ៉ាងមិចមិនដឹងទេពីដើមនិយាយគឺខ្ញុំនឹងបានភ្លេចបាត់ហើយចឹងហាសចាសហើយខ្ញុំនឹងរៀនបានខ្សោយដែលចាស៕

កៈ
បាទចឹងអត់អីនោះទេលោកយាយបាទហើយចឹងអរគុណច្រើនលោកយាយបាទហើយចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកយាយបន្ថែមទៀតថាតើនៅពេលដែលលោកយាយនៅក្នុងជំនាន់ពោលពតវិញម្ដងថាតើលោកយាយបានជួបបញ្ហាអ្វីខ្លះដែលទៅនៅក្នុងជំនាន់ពោលពតហាសលោកយាយអាចប្រាប់ខ្ញុំបានដែលរឺទេលោកយាយ???

ខៈ
ចាសសំរាប់ខ្ញុំនឹងនៅពេលដែលខ្ញុំនឹងនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងមានភាពពីបាក់ណាស់ចាសហើយខ្ញុំនឹងមិនដឹងជាយ៉ាងមិចទេចាសនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងមានភាពពីបាក់ណាស់ហើយនឹងមានភាពវេទនាដូចថាវាបានបំបែកគ្រួសាររបស់យើងហើយនឹងបងប្អូនរបស់យើងចឹងហាសចាសអោយយើងនឹងទៅឆ្ងាយឆ្ងាយអោយផុសពីឪពុកហើយនឹងម្ដាយរបស់យើងចឹងហាសនិយាយទៅគឺពួកវាមិនបានអោយយើងបានជួបគ្នានោះទេចាសហើយនៅពេលដែលយើងបានជួបហើយនឹងបានឃើញគ្នាចឹងក៏វាមិនអោយយើងនឹងបាននិយាយគ្នាដែលនិយាយគឺវាមិនអោយស្ដីរកគ្នាចឹងហាសចាសពីពួគពោលពតហើយសំរាប់ម្ដាយហើយនឹងឪពុករបស់យើងនឹងនៅពីមុខនឹងក៏វាមិនអោយយើងនឹងស្ដីរកពួកគាត់ដែលហើយពួគវាបានបំបែកខ្ញុំនឹងទៅតាមកងចាលាក់អីចឹងហាសចាសហើយនៅពេលដែលម្ដាយរបស់ខ្ញុំនឹងទៅគឺខ្ញុំនឹងនិយាយពីថាពីប្រវត្តរបស់ខ្ញុំនឹងគឺខ្ញុំនឹងគឺចង់តែទឹកភ្នែកហាសចាសដូចថានៅពេលដែលនិយាយទៅដូចជាអួលដើមករហើយខ្ញុំនឹងក៏មិនជាចង់រំលឹកដែលហាសចាសនិយាយទៅគឺរឿនអតីតកាល់ហើយសំរាប់ខ្ញុំនឹងទៅតាំងពីឆ្នាំ ១៩៧៦ វាយកទៅហើយនៅពេលដែលវាយកទៅចឹងទៅហើយម្ដាយរបស់ខ្ញុំនឹងគាត់បាននឹកខ្ញុំពេកចឹងហាសចាសហើយនៅពេលដែលគាត់បាននឹកខ្ញុំនឹងគាត់បានទៅចឹងហាសគាត់បានបាយបន្តិចនឹងគឺគាត់បានយកមកផ្ញើរអោយមកកាន់ខ្ញុំចាសដល់ពេលចឹងទៅខ្ញុំនឹងកំពុងតែឈរកាប់ដីកាប់អីចឹងទៅហើយដល់ពេលហើយចឹងទៅកាណាក់ភារៈនឹងបាននិយាយថាគឺគេបានថាអោយម្ដាយរបស់ខ្ញុំនឹងគឺគាត់បានជិតមកដល់ខ្ញុំនឹងហាសហើយពេលនឹងគេបាននិយាយថានារីនារីហូបបាយមិនបានឆ្អែកទេណាក្មួយហើយពេលនឹងគឺមានបាយតែបន្តិចបន្តិចនោះទេហើយយើងហូបចឹងទៅហើយបាយរបស់គេនឹងមានតែ ២
វែកនឹងហើយបាយនឹងគឺសសុសសសុសនឹងហើយយើងមិនបានហូបឆ្អែកហើយយើងធ្វើកំលាំងហើយពលកម្មរបស់យើងនឹងគឺវ៉ែកដីហើយនឹងជីក
ប្រឡែលចឹងទៅហាសហើយបង្គីទាំងអស់នឹងគឺធំធំខ្លាំងណាស់ហាសចាសហើយកាប់ចឹងទៅគឺវាបានបុកហើយនឹងអោយយើងនឹងវ៉ែកទៀតហាសចាសនៅក្នុងជំនាន់នឹងហើយនៅពេលដែលម្ដាយរបស់ខ្ញុំនឹងគាត់បានយកបាយអោយខ្ញុំហូបចឹងទៅហើយខ្ញុំនឹងក៏មិនដឹងជានិយាយថាយ៉ាងមិចទេចាសហើយពេលនឹងពួកពោលពតបាននិយាយថាមីកាចាស់ឯងហាសអោយតែមិត្តឯងហ៊ានឆ្លងប្រឡែលនឹងហាសអាញ់អោយយាយកាចាស់ឯងនឹងវ៉ែកដីរយះពេល១ខែចាសពួកវាបានដៀលម្ដាយរបស់ខ្ញុំនឹងចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងពីប្រវត្តរបស់ខ្ញុំនឹងចឹងគឺខ្ញុំនឹងគឺកសត់ខ្លាំងណាស់ដល់ពេលហើយចឹងទៅម្ដាយរបស់ខ្ញុំ

នឹងគឺគាត់បានទៅវិញចឹងទៅហើយគាត់មិនបានជួបទេហាសចាសនិយាយទៅគឺមិនដែលបានជួបនឹងម្ដាយរបស់ខ្ញុំនឹងនោះទេ១ឆ្នាំជាងដល់ពេលហើយចឹងទៅខ្ញុំនឹងបានប្រហែលជា៩រឺក៏
១០ថ្ងៃគេបានប្រជុំចឹងហាសហើយពេលនឹងភ្លៀវតិចតិចហើយសំរាប់ខ្ញុំនឹងបាននឹកម្ដាយរបស់ខ្ញុំនឹងពេកចឹងហាសពីព្រោះអីនឹងគឺខ្ញុំនឹងហើយនឹងម្ដាយរបស់ខ្ញុំនឹងបានបែកគ្នាជា១ឆ្នាំហើយគឺមិនដែលបានជួបមុខគ្នានោះទេហាសក្មួយហើយសំរាប់ខ្ញុំនឹងនៅខាងមូលដ្ឋានចាស់ដែលហាសចាសហើយកាល់នឹងខ្ញុំនឹងទើបតែមានអាយុ ២០ឆ្នាំ
នោះទេចាសដើរទៅហាគឺខ្ញុំមិនដល់
២០នោះទេគឺខ្ញុំនឹងមានអាយុ១៩ឆ្នាំនោះទេចាសនិយាយទៅគឺស្រុករនឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានទៅចឹងហាសគឺខ្ញុំនឹងមិនបានខ្លាចអ្វីនោះទេចាសនិយាយទៅគឺខ្ញុំនឹងដើលកាត់ព្រៃនឹងតែម្ដងហើយពេលនឹងមេឃកំពុងភ្លៀងហើយយើងនឹងក៏បានកៀកស្មារហើយទៅចឹងទៅហើយទៅដល់ដល់ផ្ទះម៉ែអើយម៉ែអើយហើយកាល់នឹងប្អូនពៅរបស់ខ្ញុំនឹងហាសទើបតែម្ដាយរបស់ខ្ញុំនឹងគាត់ទើបតែឆ្លងទន្លេងបានប្រហែលជា១ឆ្នាំហើយពេលនឹងឪពុករបស់ខ្ញុំនឹងបាននិយាយថាកូនកូនកូនឯងមកធ្វើអ្វីកូនកូនឯងតែមកចឹងហាសគឺគេនឹងសំលាប់យើងហាសហើយពេលនឹងខ្ញុំបាននិយាយថាឪពុកអើយខ្ញុំនឹកពុកហើយនឹងម៉ែណាស់ហើយនឹងនឹកបងនឹងប្អូននឹងហាសបានខ្ញុំនឹងមកនឹងហាសគ្រាន់តែភ្លេមនឹងពួកពោលពតនឹងបានឃើញខ្ញុំនឹងហាសហើយពួកវាបាននិយាយថានៃមិត្ត សយ
មិត្តឯងមកធ្វើអ្វីហាសនិយាយតែមួយភ្លេតនឹងហាសហើយពេលនឹងពួកពោលពតនឹងក៏បានហៅខ្ញុំនឹងទៅទាំងយប់ចាសហើយនៅពេលដែលគេបានហៅខ្ញុំនឹងចឹងគេបាននិយាយថាមិចមិត្តឯងមូលខ្មៅកែងមូលខ្មៅអីនឹងដើមចេញអីចឹងនិយាយទៅគឺគេនឹងប្រសបនិយាយហាសចាសហើយពេលនឹងខ្ញុំនឹងក៏បាននិយាយថាអោមិនបងអើយខ្ញុំនឹងមកលេងតែមួយភ្លួតទេហើយខ្ញុំនឹងទៅវិញហើយចឹងហាសហើយពេលនឹងគេក៏បាននិយាយដាក់ខ្ញុំនឹងវិញថាមិត្តឯងនឹងប្រកដហើយហីហើយពេលនឹងខ្ញុំនឹងបាននិយាយថាម៉ោង
៤អីនឹងគឺខ្ញុំនឹងទៅហើយចាសហើយនៅពេលដែលដល់ម៉ោងចឹងគឺមានសុទ្ធតែឈ្លបចាសគឺមានច្រើនណាស់និយាយទៅគឺពួកវានៅចាំមើលខ្ញុំនឹងចឹងហាសចាសហើយពេលនឹងខ្ញុំក៏បានគិតក្នុងចិត្តថាប្រហែលជាពួកវាវៃខ្ញុំនឹងចោលហើយមើលទៅនៅយប់នឹងហើយពេលនឹងខ្ញុំនឹងបាននិយាយថាមិត្តបងអើយម៉ោង៤អីនឹងគឺខ្ញុំនឹងទៅហើយចាសហើយពេលនឹងគឺខ្ញុំនឹងហើយគឺខ្ញុំនឹងទៅធ្វើការងារហើយគេក៏ហៅខ្ញុំនឹងទៀតហើយហៅនៅកន្លែងដំបូងហៅទៅទីកន្លែងដែលស្ងាត់ចឹងហាសហើយមានមិត្តនារីនារីដែលនៅជាមួយនឹងគ្នាគេបាននិយាយថាចេះមិត្តឯងឆ្លើយនឹងសំណួរដែលមិនត្រូវនឹងគឺយើងនឹងបានន័យថាយើងនឹងមើលងាយនឹងអង្គការរបស់គេហើយពេលនឹងខ្ញុំនឹងបាននិយាយថាសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនបានដឹងខ្លួននោះទេហើយយើងគឺយើងយកតែមួយរស់មួយរស់នោះទេហើយយើងនឹងក៏បានមានន័យថាយើងចង់មើលងាយគេដែលចឹងហាសចាសហើយពេលនឹងយើងគិតយ៉ាងមិចធ្វើអោយគេនឹងបានអាណិតយើងចឹងហាសហើយយើងខំធ្វើការងារគឺដើម្បីអោយមានជីវិតហើយនឹងបានបាយសំរាប់ចិញ្ចឹមជីវិតតែប៉ុននឹងហើយយើងបានតែបាយ២វែកដែលបាយនឹងគឺមា

នតែបន្តិចបន្តិចនោះទេចាសហើយពេលនឹងគេក៏បានហៅខ្ញុំនឹងអោយទៅហើយកាណាះកងនឹងបាននិយាយថាមិត្ត សយ

មិត្តឯងមានបានមើលងាយនឹងអង្គការដែលរឺទេហើយពេលនឹងខ្ញុំនឹងក៏បាននិយាយទៅវិញដែលថាខ្ញុំមិនបានមើលងាយអង្គការនោះទេចាសសំរាប់ខ្ញុំនឹងគឺខ្ញុំមិនដែលបានមើលងាយនឹងអង្គការនោះទេគឺខ្ញុំរស់រាល់ថ្ងៃនឹងគឺខ្ញុំរស់ដើម្បីអង្គការចាសហើយយើងនឹងចេះតែនិយាយទៅគឺដើម្បីកុំអោយគេនឹងសំលាប់យើងចឹងហាសហើយប្រសិនជាមិត្តឯងមិនបានមើលងាយនឹងអង្គការនោះទេមិត្តឯងល្អចឹងហើយពេលនឹងស្ងាត់ឆឹងហើយទួលនឹងសុទ្ធតែព្រៃហាសហើយមានខ្មោចច្រើនណាស់ដល់ពេលហើយចឹងទៅនៅពេលដែលជំនាន់ដែលខ្ញុំនឹងបានមកវិញគឺគេបានអោយខ្ញុំនឹងធ្វើការងារហើយដល់ពេលចឹងទៅខ្ញុំនឹងការងារបាន៤រឺក៏៥ថ្ងៃចឹងទៅគឺតែបានបញ្ចូលខ្ញុំនឹងទៅរហូតបញ្ចូលបញ្ចូលមកអោយធ្វើការងារដូចជាការដាំស្ពីហើយនឹងដាំអីអីនឹងគឺដាំស្របគ្រប់ហើយនឹងដាំដំឡូរចាសហើយនៅពេលដែលយើងដាំបានអីចឹងទៅគឺវាមិនបានអោយយើងបានហូបនោះទេចាសហើយកាល់ដែលនៅក្នុងជំនាន់នឹងយើងចេះតែខំប្រឹងធ្វើចឹងទៅហើយសំរាប់ដំណាំដែលយើងនឹងបានធ្វើចឹងគឺយើងមិនបានដឹងគេយកទៅណានោះទេអោយតែយើងនឹងបានធ្វើចឹងទៅហើយនឹងដើម្បីអោយបានបាយសំរាប់ហូបចឹងទៅហើយគេនឹងបានបញ្ចូលខ្ញុំទៅរហូបហើយនិយាយចឹងទៅគឺខ្ញុំនឹងបានបែកពីបងហើយនឹងប្អូនទាំងអស់ហើយបងប្អូនរបស់ខ្ញុំនឹងគឺវេទនាណាស់ហើយនឹងម្តាយរបស់ខ្ញុំនឹងហើយនឹងគេបានយកឪពុករបស់ខ្ញុំនឹងយកទៅសំលាប់ចោលចាសហើយនៅពេលដែលគេគេបានយកឪពុករបស់ខ្ញុំនឹងយកទៅសំលាប់ចោលចឹងហើយគេក៏បានយកម្តាយរបស់ខ្ញុំនឹងយកទៅដាក់កងស្រួចទៀតហើយឪពុករបស់ខ្ញុំនឹងគាត់និយាយថាខ្ញុំនឹកកូនណាស់ហើយប្រសិនជាស្លាប់ជាអីនឹងសូមអោយបានជួបនឹងខ្ញុំហើយខ្ញុំគឺមិនបានជួបនឹងគាត់នោះទេចាសនិយាយទៅតាំងពីឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៨

ចាសគេបានយកឪពុករបស់ខ្ញុំនឹងយកទៅសំលាប់ចោលហើយក៏ខ្ញុំនឹងមិនដែលបានជួបនឹងឪពុករបស់ខ្ញុំដែលចាសហើយនៅពេលដែលខ្ញុំនឹងនិយាយប្រវត្តរបស់ខ្ញុំនឹងគឺខ្ញុំមានអាម្មរណ៏ថាឈឺចាប់ខ្លាំងណាស់ដល់ពេលហើយចឹងទៅអោយម្តាយរបស់ខ្ញុំនឹងរៀបគ្រួសារចឹងទៅហើយគេបានយកឪពុករបស់ខ្ញុំនឹងយកទៅសំលាប់ចោលហើយសំរាប់បងប្អូនរបស់ខ្ញនឹងគឺជាបងប្អូនជីដូនមួយរបស់ខ្ញុំនឹងក៏គេបានយកទៅសំលាប់ចោលដែលចឹងហាសចាសនិយាយគឺពួកពោលពតនឹងវាយកទៅសំលាប់ទាំងអស់តែម្តងហាសចាសនិយាយទៅបងប្អូនរបស់ខ្ញុំនឹងស្លាប់ទាំងអស់ចាសនៅពេលដែលខ្ញុំនឹងនិយាយពីប្រវត្តរបស់ខ្ញុំនឹងគឺខ្ញុំមិនដែលបានជួបមុខឪពុករបស់ខ្ញុំនោះទេហើយនិយាយទៅគឺខ្ញុំនឹកឪពុករបស់ខ្ញុំនឹងគឺពួកវាគេបានយកឪពុករបស់ខ្ញុំនឹងយកទៅសំលាប់ចោលដូចជាហូសហេតិពេកហើយនៅក្នុងជំនាន់ពោលពតហាសលោកក្មួយហាសចាសបិននឹងបិននឹងហាសចាសនៅពេលដែលយើងបានសួរម្តាយហើយនឹងឪពុកយើងចឹងគឺគេយកទៅសំលាប់ចោលចាសក្មេងបិននឹងគឺនៅកំព្រឹងចាសហើយក៏មានខ្លះនឹងគេបានសំរាប់ចោលនៅក្នុងអណ្តូងចោលចឹងទៅចាសនៅពេលដែលខ្ញុំនឹងបាននិយាយពីពួកពោលពតគឺខ្ញុំនឹងវាពីបាក់ខ្លាំងណាស់ហើយក៏ខ្ញុំនឹងឆ្អែតដែលនៅក្នុងជំនាន់ពោលពតនឹងចាសហើយសំរាប់បងប្អូននឹងគឺបានបែកបាក់គ្នាចឹងទៅហើយនៅពេ

លដែលបានឃើញគ្នាចឹងក៏មិនបានអោយនិយាយរកគ្នាចាសនិយាយទៅសព្វគ្រប់តែម្តងហាសចាសនឹងហើយឪពុករបស់ខ្ញុំនឹងគឺគាត់បានស្លាប់នៅក្នុងជំនាន់ពោលពតបាត់ឆឹងរហូតហើយម្តាយរបស់ខ្ញុំនឹងគឺកាត់ទើបតែស្លាប់ពេលនឹងនោះទេហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងគឺខ្ញុំនឹងមិនដែលបានជួបមុខគ្នានោះទេអូនលោកក្មួយទើបតែនៅពេលដែលបានគេរំដោះបាននោះទេដែលបានជួបជុំបងប្អូនរបស់ខ្ញុំនឹងហាសចាសនិយាយទៅបែកគ្នារហូតបងប្អូនចាសគឺបែកទាំងអស់ចាសហើយគឺពួកពោលពតនឹងបានធ្វើបាប់ប្អូនរបស់ខ្ញុំនឹងខ្លាំងណាស់វៃប្អូនរបស់ខ្ញុំនឹងហើយក៏មិនបានអោយបាយក្មេងក្មេងដែលជាកុមារនឹងហាសគឺមិនបានអោយហូបបាយបានឆ្អែតហើយអោយពួកគេនឹងទៅច្រូតធៀនអីចឹងទៅហាសចាសហើយនៅពេលដែលគ្នាមិនបានទៅចឹងទៅគឺគេបានវៃគ្នាចាសនិយាយពីនៅក្នុងជំនាន់ពោលពតនឹងគឺវេទនាណាស់លោកក្មួយអើយខ្ញុំនឹងលោកក្មួយឯង៕

ក៖
បាទចឹងអរគុណច្រើនលោកយាយហើយចឹងកាល់លោកយាយនៅជំនាន់ពោលពតថាតើគេអោយលោកយាយរស់នៅខេត្តណាដែលវិញទៅលោកយាយ???

ខ៖
ចាសនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានរស់នៅខេត្តកណ្តាលស្ទឹងចាសគឺនៅប្រដោលហើយនៅពេលដែលកងនារីគឺគេបានអោយដើលចល័តហើយអោយយើងនឹងបានមកនៅទឹកថ្លានេះនៅទឹកថ្លានារីនារីគេក៏បានប្រមូលដាក់តាមភារះដូចជាកងទ័ពចឹងហាសចាសដាក់តាមភារះដាក់តាមភារះអីចឹងទៅដាក់តាមភារះ១ដាក់តាមភារះ២ដាក់តាមភារះ៣អីចឹងទៅហាសតាមភូមិនារីចឹងទៅហាសចាសនារីដាក់តាមមួយភារះផ្សេងចឹងទៅហើយសំរាប់ដូចយុវជនហើយដូចថាគេដាក់តាមភារះ ១ ដាក់តាមភារះ ២ ដាក់តាមភារះ ៣ ដាក់តាមភារះ ៤
ដាក់តាមភារះ៥ចឹងទៅហាសហើយសំរាប់យុវជនហើយនឹងនារីចឹងទៅហាសអូនហាសចាសគឺគេមិនបានអោយរស់នៅជាមួយនឹងគ្នានោះទេគឺគេអោយនៅផ្សេងផ្សេងពីគ្នាដាក់តាមភារះប្រុសប្រុសផ្សេងចឹងទៅហើយសំរាប់ស្រីគឺគេអោយនៅផ្សេងចឹងទៅហាសចាសហើយនៅពេលដែលពួកគេបានឃើញមុខគ្នាគឺគ្មាននាក់ណាហ៊ាននិយាយរកគ្នានោះទេគឺខ្លាចគេយកទៅវៃចោលចឹងហាសហើយសុំបីតែម្ហូបហើយនឹងអាហារគឺជាក្តាមហើយនឹងខ្យននឹងក៏វាមិនបានអោយយើងនឹងបានរើសដែលនិយាយគឺវាមិនអោយរើសតែម្តងហើយប្រសិនជាយើងនឹងរើសហូបហើយនឹងដាក់នៅក្នុងចង្កេះហើយមិត្តឯងនឹងកម្មសិទ្ធក្រាសម្លេះគ្រាន់តែខ្យងនឹងក៏វាមិនបានអោយយើងដែលនិយាយគឺពិបាក់ណាស់ក្មួយអើយសុទ្ធតែយើងនឹងកម្មសិទ្ធក្រាសកូនអាណៀលទុនប្រកិកិរិយានឹងហើយនៅពេលដែលយើងរើសបានចឹងគឺយើងនឹងបានបោះវាចោលចឹងទៅគឺយើងមិនហ៊ានហូបនោះទេហើយសំរាប់បាយនៅពេលដែលគេអោយហូបបានបិនណាគឺបិននឹងហើយគឺគ្មានតវាអីណាខ្ញុំនឹងបិននឹងគឺមិនបានឆ្អែតនោះទេហើយប្រសិនជាយើងនឹងហ៊ានតវ៉ាជាមួយនឹងពួកវាគឺវាយកយើងនឹងទៅវៃចោលនិយាយទៅពួកពោលពតនឹងគឺមិនបាននោះទេចាស៕

ក៖

បាទហើយចឹងនៅពេលដែលនៅក្នុងជំនាន់ពោលពតលោកយាយរស់នៅខេត្តកណ្ដាលស្ទឹងមែនដែលលោកយាយហើយចឹងនៅក្នុងជំនាន់ថាតើគេមានបានអោយលោកយាយធ្វើការងារអ្វីដែលពិបាក់ពិបាក់ជាងនឹងដែលរឺទេដូចជាការងារដកស្ទុងរឺក៏ទៅធ្វើអ្វីផ្សេងផ្សេងគេមានបានអោយលោកយាយធ្វើដែលរឺទេលោកយាយ???

ខ៖

ចាសមានគឺដកស្ទុងដូចថាខែស្ទុងគឺស្ទុងហើយសំរាប់ខែច្រូតគឺច្រូតហើយសំរាប់ខែណាដែលគេជីកប្រឡាយគឺជីកប្រឡាយនិយាយទៅគឺហត់ណាស់លោកក្មួយហើយយប់ពេលណាក៏អោយយើងនឹងធ្វើដែលហើយនៅពេលដែលធ្វើហាសហោះនារីទៅច្រូតស្រូវហើយនឹងទៅដកស្រូវហើយយើងនឹងទៅហើយយប់ដល់ណាក៏យើងទៅដែលហើយនៅពេលដែលម៉ោង៩រឺក៏ម៉ោង១០នឹងគឺយើងដើលវ៉ាល់ចាសនិយាយទៅគឺវេទនាណាស់លោកក្មួយហើយគេបានអោយយើងនឹងបានជីកហើយនឹងដាក់ប្រឡាយហើយនៅពេលដែលយើងនឹងធ្វើហើយពេលណាគឺគេដកយើងនឹងទៅទ្រាមខ្សែរពេលនឹងចាសនិយាយទៅគឺយើងនឹងពិបាក់វេទនាខ្លាំងណាស់លោកក្មួយវេទណាស់ហើយគេយើងនឹងរ៉ែកដីរ៉ែកអីនឹងគឺខានមិនបាននោះទេហើយគេអោយយើងនឹងរ៉ែកដីមួយថ្ងៃរហូតដល់ល្ងាចហើយដល់ម៉ោង៩រឺក៏ម៉ោង១០ទៀតហើយនៅពេលដែលយើងបានហូបបាយហើយចឹងគឺគេបានអោយយើងនឹងទៅរ៉ែកទៀតចាសដូចថាក្មេងលូវនឹងគឺគ្មានស្គាល់ថាភាពលំបាក់ដូចកាលនៅក្នុងជំនាន់ពោលពតនោះទេហើយនឹងដូចជំនាន់របស់ខ្ញុំដែលចឹងហាសចាសនិយាយកាល់ដែលនៅក្នុងជំនាន់របស់ខ្ញុំនឹងគឺវេទនាខ្លាំងណាស់ចាសហើយនៅពេលដែលយើងនឹងពិបាក់ហើយគឺយើងនឹងមិនបានហូបឆ្អែតទៀតប្រសិនជាពិបាក់ហើយអោយយើងនឹងបានហូបឆ្អែតអីទៅគឺវាមិនអីនោះទេចាសហើយអោយយើងនឹងធ្វើការងារដូចជារ៉ែកដីនឹងគឺសុទ្ធតែកំលាំងស្រួចស្រួចដែលជានារីនារីហាសហើយសំរាប់បង្គីនឹងគឺសុទ្ធតែធំធំហើយនៅពេលដែលយើងនឹងរ៉ែកគឺគេបានដាក់យើងនឹងសុទ្ធតែក្របុំហើយហើយគេបានយកជាប់កាប់បុកដីអោយវាបានណែនថែមទៀតហើយសំរាប់យើងនឹងចេះទេទៅចឹងទៅហើយសំរាប់ខ្ញុំនឹងកាល់ដែលខ្ញុំនឹងនៅក្នុងជំនាន់នឹងគឺខ្ញុំនឹងស្គមហើយក្បាលរបស់ខ្ញុំនឹងគឺត្រមែនកាល់នៅជំនាន់ពោលពតហូបមិនបានឆ្អែត៕

ក៖

បាទចឹងនៅពេលដែលលោកយាយគេបានអោយធ្វើការងារដែលលំបាក់ហើយនឹងហួសកំលាំងថាតើលោកយាយមានជំងឺអ្វីខ្លះដែលទេលោកយាយ???

ខ៖

ចាសសំរាប់ខ្ញុំនឹងឈឺដែលចឹងហាសកាលដែលខ្ញុំនឹងនៅក្នុងជំនាន់ពោលពតហើយខ្ញុំនឹងឈឺហើមចាសគឺខ្ញុំនឹងហើមជើងចាសសនិយាយគឺជាជំងឺហើមតែម្ដងចាសហើយនៅពេលដែលខ្ញុំឈឺហើមចឹងគឺខ្ញុំនឹងញ្ញែកហើយនៅពេលដែលខ្ញុំនឹងឈឺចឹងចេះតែតស៊ូចឹងទៅគឺដើ

ម្បីរស់ចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានញ្លែកចឹងទៅគឺខ្ញុំនឹងបានយកអាស្លឹកស្ដៅហើយកាច់ស្លឹកស្ដៅយកទៅច្របាច់ហើយហូបចឹងទៅចាសគឺឈឺបណ្ដាលហើយនឹងធ្វើការងារបណ្ដាលចឹងទៅ៕

ក៖
បាទហើយចឹងពួកពោលពតនឹងគេមិនបានផ្ដល់ថ្នាំសំរាប់អោយលោកយាយដើម្បីព្យាបាលអោយលោកយាយអីទេមែនដែលទេលោកយាយ???

ខ៖
ចាសគេអោយខ្ញុំដែលចឹងហាសតែគេបានអោយថ្នាំនឹងដូចជាអាចន៍ទន្សាយចឹងហាសនិយាយទៅ០០គ្រាប់ហើយយើងហូបចឹងទៅនិយាយទៅគឺមិនដូចជាថ្នាំរបស់យើងលូវនឹងណាថ្នាំគ្រាប់គ្រាប់ដូចជាអាចន៍ទន្សាយហូបអីបានជាពីព្រោះអីនឹងយើងមិនបានដឹងថាវាជាថ្នាំអ្វីនោះទេមិនដូចជាថ្នាំរបស់យើងលូវនឹងណាថ្នាំហាដូចជាថ្នាំ
ប៉ារ៉ាអំពីស៊ីលអំពីស៊ីលហើយយើងមិដឹងថាវាជាថ្នាំអ្វីថ្នាំអ្វីចាសខ្ញុំនឹងមិនដែលបានហូបទេគឺខ្ញុំនឹងហូបតែស្លឹកស្ដៅនោះទេ៕

ក៖
បាទហើយនៅពេលដែលលោកយាយបានហូបថ្នាំនឹងចឹងទៅថាតើលោកយាយបានធូរបានខ្លះដែលរឺទេលោកយាយរឺក៏យ៉ាងមិចដែល???

ខ៖
ចាសនិយាយទៅវាអាចត្រជាក់ដែលនៅពេលដែលខ្ញុំនឹងបានហូបស្ដៅហាសហើយហែមសុវត្ថិគាត់ហូបមួយម្ដងគឺមួយផ្ដោលមួយផ្ដោលចាសហើយនៅពេលដែលយើងហូបទៅវាបាត់ចឹងទៅគឺយើងចេះតែធ្វើការងារទៀតចឹងទៅចាសនិយាយទៅគឺខ្ញុំនឹងតស៊ូហើយសំរាប់ងប្អូនរបស់ខ្ញុំនឹងក៏ចឹងដែលហើយយើងចេះតែតស៊ូចឹងទៅបើលមិនចឹងទេគឺវាសំលាប់យើងចោលអស់ហើយចាសហើហយវាថាយើងនឹងគឺជាកូននាទន់អីណាហោះចាសតាមកាពិតយើងគឺជាកូនអ្នកក្រីក្រនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលលោកយាយបានហូបថ្នាំងស្ដៅនឹងបានជាសះស្បើយហើយលោកយាយបានទៅធ្វើការងារទៀតហើយហើយគេមានអ្វីដែលធ្វើការងារដែលពិបាក់ជាងនឹងទៀតដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺធ្វើតែបិននឹងចាសខាងនារីច្រូតស្រូវចាសហើយនៅពេលដែលដល់ខែជីកប្រឡាយយើងជីកប្រឡាយចឹងទៅចាសហើយសំរាប់ខ្ញុំនឹងគឺច្រូតស្រូវផងដូចគេថាគេចាប់កំលាំងហាសមិត្តឯងនឹងគឺទៅច្រូតស្រូវហើយមិត្តឯងនឹងទៅស្រោចបន្លែចាសតាមតែគេ

ចាប់ចែងយើងហាសចាសហើយនិយាយទៅការងាររបស់ខ្ញុំនឹងគឺមិនទៀងនោះទេគឺវាចល័តរហូតចាស៕

ក៖
បាទហើយចឹងនៅពេលដែលលោកយាយទៅធ្វើចឹងថាតើគេមានបានផ្តល់ជារង្វាល់អោយទៅកាន់លោកយាយដែលរឺទេលោកយាយ???

ខ៖
ចាសគឺគ្មាននោះទេលោកក្មួយអោយតែបាយហូបមិនបានឆ្អែតផងបានរង្វាល់ពីណាមកបាយហូបមិនបានឆ្អែតផងបាយបានតែ២វែកហើយសសោះអាស្លាបព្រាជំឡួរហើយដាក់ស្ករហើយក៏ចែកគ្នាហើយសំរាប់សំល្លរត្រកួនអីនឹងនិយាយទៅខ្មៅក្រើបតែម្តងហាសចាសហើយនៅពេលដែលយើងហូបសំល្លត្រកួននឹងគឺធ្មេញរបស់យើងនឹងគឺខ្មៅណាស់ចាសនិយាយមិនដូចជាល្វនឹងនោះទេដឹងគេស្លរយ៉ាងមិចនោះទេស្លឹកអំពៅគឺគេបានបូតស្លឹកណាដែលចាស់ចាស់ដូចជាមែកស្វាយចឹងហាសគេបានកាប់មកមួយធៀងមកហើយដាក់ស្លរហើយសំរាប់យើងនឹងអត់មានអីហូបចឹងគឺយើងចេះតែហូបចឹងទៅចាសសូម្បីតែអំបិលនឹងក៏គ្មាននឹងហូបផងចាសនៅក្នុងជំនាន់នឹងគឺវេទនាណាស់ចាស៕

ក៖
បាទហើយចឹងលោកយាយមានបានចាំថានៅពេលដែលលោកយាយពិបាក់ចឹងថាតើនៅជំនាន់ណាដែលដែលគេបានជួយរំដោះខ្មែរយើងហាសហើយនៅពេលដែលគេបានជួយរំដោះហើយថាតើលោកយាយបានភៀសខ្លួនទៅទីកន្លែងណាវិញដែលទៅលោកយាយ???

ខ៖
ចាសនៅពេលដែលគេបានរំដោះនឹងចាសសំរាប់ខ្ញុំនឹងគឺកាល់នឹងគឺខ្ញុំគេគ្រាប់គ្នានឹងបានរត់ទៅភ្នំពេញហើយពេលនឹងគឺពួកពោលពតនឹងវាចេះហ៊ានមិត្តឯងនាំមិត្តឯងទៅនោះហើយនៅពេលដែលពួកវាបាននិយាយចឹងទៅគឺវាយកកាប់ភ្លើងយកមកផ្ទុងយើងហាសចាសហើយពេលនឹងបងប្អូនរបស់ខ្ញុំនឹងគឺមានចំនួន
៨នាក់ហើយសំរាប់ខ្ញុំនឹងបងគេហើយខ្ញុំនឹងមានប្អូនប្រុសរបស់ខ្ញុំនឹងគឺនៅតូចហើយនៅពេលនឹងគឺម្តាយរបស់ខ្ញុំនឹងឈឺទៀតហើយសំរាប់រទេះនឹងគឺយើងអូសចឹងទៅគឺអូសមិនរួចនោះទេហើយសំរាប់កាប់ភ្លើងយកមកផ្ទុងយើងរហូតចឹងហាសហើយនៅពេលដែលវាយកកាប់ភ្លើងយកមកផ្ទុងយើងចឹងទៅពេលនឹងម្តាយរបស់ខ្ញុំនឹងគាត់បាននិយាយថាកូនឯងទៅចុះមើលតែម្តាយនឹងត្រូវស្លាប់នៅទីនឹងហើយហើយពេលនឹងខ្ញុំនឹងបាននិយាយថាម៉ែអើយម៉ែអើយម៉ែមិនស្លាប់នោះទេហើយនៅពេលដែលខ្ញុំនឹងបាននិយាយហើយចឹងគឺខ្ញុំនឹងបានដាក់ម្តាយរបស់ខ្ញុំនឹងទៅនឹងរទេះហើយខ្ញុំនឹងបានអូសទៅទៀតហើយដល់ពេលហើយចឹងទៅគឺពួកវាបានចេញទៅបាត់ចឹងទៅចាសហើយពេលនឹងមានប្រជាជនច្រើនចឹងទៅគឺខ្ញុំនឹងចេះតែទៅតាមគេចឹងទៅហាសចាសដល់ពេលហើយខ្ញុំនឹងចេះតែកិចហើយគេបាននិយាយថាយើងទាំងអស់គ្នាកុំទៅទីកន្លែងនឹងនៅពេលដែលយើងទៅទីកន្លែងនឹងពួកវានឹងសំលាប់

យើងចោលហើយចាសគឺអ្នកប្រជាជនដែលថ្មីថ្មីនឹងគាត់ចេះតែនិយាយចឹងទៅហាសដល់ពេលហើយចឹងទៅគឺគេបានបបួលគេឡើងមកចឹងទៅហើយសំរាប់ខ្ញុំនឹងខ្ញុំនឹងបាននិយាយថាប្រសិនជាមានអ្នកណាដែលបានមករំដោះខ្ញុំនឹងគឺខ្ញុំនឹងមិនភ្លេចគុណអ្នកនោះទេអោយតែខ្ញុំនឹងរស់រានមានជីវិតគឺខ្ញុំនឹងមិនភ្លេចគុណនោះទេចាសនិយាយទៅគឺខ្ញុំនឹងមិនភ្លេចគុណមែនលោកក្មួយចាសហើយនៅសព្វថ្ងៃនឹងបងប្អូនរបស់ខ្ញុំនឹងបានមានជីវិតនឹងគឺខ្ញុំនឹងមិនបានភ្លេចគុណនោះទេចាសគឺខ្ញុំនឹងនិយាយមែនពីព្រោះអីទំរាំមបានមានជីវិតបានមកដូចល្ងវនឹងតែប្រសិនជានៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងស្លាប់បាត់ហើយហើយក៏បងប្អូនរបស់ខ្ញុំនឹងក៏ស្លាប់ទាំងអស់ដែលគឺគ្មានសល់នោះទេចាសនិយាយទៅគឺស្លាប់តែឪពុករបស់ខ្ញុំទេណាចាសហើយសំរាប់បងប្អូនរបស់ខ្ញុំនឹងទាំង ៨
នាក់គឺគាត់មានជីវិតទាំងអស់ចាសនៅពេលដែលគេបានមករំដោះចឹងមកខ្ញុំនឹងក៏បានមកនៅភ្នំពេញចាសហើយនៅពេលដែលខ្ញុំបានមកនៅភ្នំពេញគឺខ្ញុំនឹងបានមកនៅទីកន្លែងនឹងតែម្ដងហាសចាសពីមុននឹងគឺខ្ញុំនឹងនៅទីន្លែងចាក់សំរាមហើយនៅពេលដែលចាក់សំរាមខ្ញុំនឹងក៏បានមកនៅទីកន្លែងនេះមកចាសហើយយើងដើរទៅនៅគ្រាប់ទីកន្លែងនឹងហើយសំរាប់ម្ដាយរបស់ខ្ញុំគឺគេបានចែកផ្ទះចឹងតែម្ដាយរបស់ខ្ញុំនឹងគឺគាត់មិនចង់ងបាននោះទេនិយាយគឺគាត់បាក់ស្បាតគាត់ហើយគាត់បាននិយាយថាកូនឯងកុំនៅផ្ទះធំធំណានៅផ្ទះតូចតូចបានវាមានភាពងាយស្រួលរត់ហាសគាត់បាក់ស្បាតកាល់គាត់នៅក្នុងជំនាន់ពោលពតហាសចុះនៅពេលដែលបែកនឹងគឺវាបានផ្ទុងយើងហើយវាចេះតែអោយយើងនឹងទៅតាមវាហើយនៅពេលដែលវាផ្ទុងយើងយើងនឹងមិនទៅគឺមិនបានចាសហើយយើងចេះតែទៅតាមវាហើយនៅពេលដែលបានរត់ទៅក្រោយពេលនឹងគឺយើងរត់ទៅមុខដូចជាឈ្វរឈរចាសនិយាយទៅគឺមានប្រជាជនរាប់ពាន់ណាលោកក្មួយចាសហើយយើងចេះតែដើរទៅដើរមកដើរទៅដើរមកហើយអ្នកណាដែលខ្លាចចឹងទៅគេចេះតែទៅតាមវាចឹងទៅចាសហើយនៅពេលនឹងគឺស្លាប់មិនចេះតិចទេណាលោកក្មួយចាសខ្មែរយើងចាស៕

ក៖
បាទហើយចឹងអ្នកដើរទៅមុខហើយកាន់កាំភ្លើងគាត់មានវ័យចំណាស់រឺក៏វ័យក្មេងដែលទៅលោកយាយ???

ខ៖
ចាសនិយាយទៅគឺសុទ្ធតែមានអាយុ២០ឆ្នាំជាងចាសគឺមានក្មេងខ្លះហើយនឹងចាស់ខ្លះចឹងទៅចាសហើយគ្នាពួកវានឹងគឺមានគ្នាចំនួនតែ ៤នាក់រឺក៏ ៥នាក់នោះទេចាស៕

ក៖
បាទប៉ុនតែនៅក្នុងជំនាន់គឺមានមនុស្សចងរាប់ពាន់ចងទាំងខ្សែរទាំងខ្សែរគឺដើម្បីដើរទៅអីចឹងក៏ប៉ុនតែពួកវានឹងគឺមានគ្នាចំនួនតែ ៤នាក់រឺក៏ ៥នាក់នោះទេមែនដែលទេលោកយាយ???

ខ៖
ចាសវាចងខ្សែរនៅពេលដែលយើបានបែកហាសចាសតែកាល់ពីយើងនៅពេលដែលយើង

ចុះទៅដូចជានៅក្នុងឆ្នាំ ១៩៧៦
គឺពួកវាបានធ្វើជាប្រវត្តរូបអីចឹងហើយមានអ្នកខ្លះនឹងពួកវាអាចចងខ្សែរយកទៅដែលហាស តែពួកវាមិនដឹងជាយកទៅណានោះទេហើយមានសុទ្ធតែប្រុសប្រុសក្មួយអើយស្អាតដូចជាក្មួយនឹងហាសចុះអាយើងដែលទើបតែបានចេញពីភ្នំពេញហាសចាសទៅគឺហើយគឺគេយកទៅបាត់ហើយយកទៅសំលាប់ចោលអស់គឺគ្មានសល់នោះទេបងបងគេវៃហើយនឹងបងប្អូនជីដូចមួយនឹងគឺគេយកទៅសំលាប់ចោលអស់ហើយ៕

ក៖
ចឹងបាននៃថាគេយកតែបងប្អូនរបស់លោកយាយជីដូចមួយនឹងគឺគេយកទៅសំលាប់ចោលអស់បាទហើយចឹហាបងប្អូនរបស់លោកយាយមានគ្នាចំនួនប៉ុន្មាននាក់ដែលលោកយាយ???

ខ៖
ចាសបងប្អូនរបស់ខ្ញុំនឹងមាន៧នាក់រឺក៏៨នាក់ដែលមានសុទ្ធតែប្រុសប្រុសចាសគឺគេបានយកទៅចាសគឺមានស្រីហើយនឹងប្រុសចឹងទៅណាគឺគេយកទៅសំលាប់ចោល៕

ក៖
បាទហើយចឹងបងប្អូនជីដូចមួយរបស់លោកយាយនឹងលោកយាយមានបានចាំឈ្មោះរបស់ពួកគាត់ដែលរឺទេលោកយាយអ្នកដែលគេយកទៅសំលាប់ចោលហាស???

ខ៖ ចាសអ្នកដែលគេយកទៅសំលាប់ចោលនឹងគឺខ្ញុំនឹងបានចាំចាសទី១នឹងគឺបង ផន ហើយទី២បង ពន ហើយទី៣នឹងបង ផៃ ហើយនឹងទី៤បង វណ្ណថន ហើយនឹងទី៥បង ឆុន ចាសនិយាយទៅគឺស្លាប់គឺច្រើនណាស់ហើយសំរាប់៣នាក់ទៀតរឺក៏៤នាក់ទៀតគឺខ្ញុំនឹងបានភ្លេចដែលហើយចឹងហាសចាសគេយកទៅសំលាប់ចោលនឹងជីដូចមួយចាសដែលគាត់បានបែកគ្នាគ្នាទៅហាសក្មួយចាស៕

ក៖
បាទហើយចឹងបានន័យថាបងប្អូនជីដូចមួយរបស់លោកយាយនឹងមានចំនួន៨នាក់ហើយនឹងបងប្អូនបង្កើតនឹងមានចំនួន៨នាក់ដែលមែនដែលទេលោកយាយ???

ខ៖
ចាសនឹងគឺបងប្អូនជីដូចមួយដែលមួយពោះមួយពោះហើយសំរាប់អ្នកសាច់ឆ្ងាយនឹងគឺគេបានស្លាប់អស់ច្រើនណាស់ហើយមានអ្នកខ្លះនឹងបានយកទៅខេត្តបាត់ដំបងហើយនឹងខេត្តអ្វីផ្សេងផ្សេងចឹងហាសចាសហើយនៅពេលដែលបានទៅដល់ទីកន្លែងនោះគឺវាបានបំបែកអោយទៅនោះទៅនោះអីចឹងទៅចាសបងប្អូនជីដូច១របស់ខ្ញុំនឹងគឺមានចំនួនច្រើនដែលតែពួកគាត់បានស្លាប់អស់ហើយចឹងទៅនិយាយទៅគឺពួកគាត់បានស្លាប់ច្រើនណាស់នៅជំនាន់ពោលពតចាស៕

ក៖
បាទហើយចឹងបានន័យថាតែបងប្អូនរបស់លោកយាយដែលជាបងប្អូនជីដូច១របស់ដែលគេបានយកទៅសំលាប់ចោលមែនដែលទេលោកយាយ???

ខ៖
ចាសគឺមានបងប្អូនជីដូច១របស់ខ្ញុំនឹងដែលនៅបាត់ដំបងនឹងបានស្លាប់ច្រើនណាស់ដែលចឹងហាសនិយាយទៅនៅពេលដែលគេបានទៅនឹងមានចំនួន៣រឺក៏៤គ្រួសារនឹងបានស្លាប់អស់ហើយចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានសំលាប់បងប្អូនរបស់លោកយាយហើយចឹងហើយនៅក្នុងជំនាន់នឹងគេបានរំដោះលោកយាយចេញពីជំនាន់ពោលពតនឹងថាតើនៅក្នុងជំនាន់ពោលពតនឹងថាតើលោកយាយបានជួបជុំគ្នាជាមួយនឹងក្រុមគ្រួសាររបស់លោកយាយវិញមែនដែលទេលោកយាយហើយនៅពេលដែលលោកយាយបានជួបជុំគ្នាជាមួយនឹងក្រុមគ្រួសាររបស់លោកយាយថាតើលោកយាយរត់មករស់នៅទីកន្លែងណាដែលទៅលោកយាយ???

ខ៖
ចាសនិយាយទៅនៅពេលដែលខ្ញុំនឹងបានជួបជុំគ្នាជាមួយនឹងក្រុមគ្រួសាររបស់ខ្ញុំនឹងមុនដំបូងនឹងគឺខ្ញុំនឹងទីកន្លែងនោះចាសគឺម៉ុំចាក់សំរាមហាសចាសខាងនឹងពីមុនគេហៅថាខាងបដវត្តិហាសពីមុនចាសគឺគេបានដាក់សង្កាត់បដវត្តិតែសំរាប់ល្ងវនឹងគឺគេបានប្តូរអស់ហើយគឺគេបានដាក់ខាងព្រែកឬស្សីអីចឹងទៅហាសចាសហើយពេលនឹងគឺខ្ញុំនឹងក៏បានមករស់នៅខាងស្ទឹងជ្រៅនេះវិញមកនិយាយទៅដូចថាយើងដើរទៅរស់នៅហាសលោកក្មួយចាសដើរទៅរស់នៅដូចជាកំសត់ចាសនិយាយទៅដូចជាកំសត់ខ្លួនដូចថានៅទីកន្លែងនេះបន្តិចនៅទីកន្លែងនោះបន្តិចក៏ប៉ុនតែសំរាប់នៅទីកន្លែងគឺបានយូរណាស់ចាសនៅទីន្លែងនេះជាង ៣០ឆ្នាំជាងហើយចាស៕

ក៖ បាទហើយចឹងនៅពេលដែលលោកយាយបានមករស់នៅទីកន្លែងនេះជា ៣០ឆ្នាំហើយថាតើរដ្ឋគឺគេជាអ្នកអោយលោកយាយរឺក៏លោកយាយមករសើនៅទីកន្លែងនឹងតែម្តងរឺក៏យ៉ាងមិចដែលទៅលោកយាយ???

ខ៖
ចាសសំរាប់ដីនេះគឺពីមុននឹងគឺខ្ញុំនឹងនៅទីកន្លែងនោះទេតែរដ្ឋក៏បានចែកអោយខ្ញុំនឹងដូចថាយើងនៅបាន១ផ្ទះហើយនឹងបាន២ផ្ទះហើយនៅពេលដែលយើងមិននៅចឹងគឺយើងលក់អីចឹងទៅគឺក្នុងតម្លៃថោកថោកចឹងទៅហាសចាសហេហេហេហើយយើងក៏ចេះតែមករស់នៅទីកន្លែងនេះទៀតចឹងទៅចាសសំរាប់ដីនេះគឺខ្ញុំនឹងជាអ្នកទិញនោះទេលោកក្មួយពីព្រោះអីនឹងយើងបានមករស់នៅទីកន្លែងនៅក្នុងឆ្នាំ

១៩៨០ជាងហើយហាសចាសបានរស់នៅទីកន្លែងនេះឆ្នាំ
១៩៨០ជាងហើយចាសសំរាប់ដីនៅទីកន្លែងនេះយើងទិញគេនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានបែកនៅក្នុងជំនាន់ពោលពតនឹងដែលគេបានរំដោះយើងហាសលោកយាយចឹងលោកយាយមានបានទៅរើសអីវ៉ាន់ពីខាងនៅក្នុងភ្នំពេញរឺក៏នៅទីកន្លែងដែលពួកពោលពតគេបានប្រមូលរបស់របបដែលជារបស់ប្រជាជនគេបានទុក្ខចោលលោកយាយថាតើលោកយាយបានទៅប្រមូលរបស់របបដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយគឺខ្ញុំនឹងមិនបានទៅប្រមូលរបស់របបដែលទុក្ខចោលនឹងនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងមិនហ៊ាននោះទេនិយាយគឺខ្ញុំនឹងមិនហ៊ានតែម្តងតែសំរាប់គេដែលជាអ្នកហ៊ាននឹងគឺគេបានទៅដឹកទូដឹកអីចឹងទៅតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនហ៊ានពីព្រោះអីម្តាយរបស់ខ្ញុំនឹងគាត់បាននិយាយថាកូនអើយយើងកុំយករបស់គេអីនិយាយទៅសុទ្ធតែទ្រព្យរបស់គេចឹងហើយយើងកុំទៅយកអីចាសនិយាយគឺខ្ញុំនឹងមិនហ៊ានតែម្តងចាសហើយសំរាប់ខ្ញុំនឹងបានបិនណាគឺខ្ញុំនឹងរស់បិននឹងហេហេហេហើយនឹងមានហូបបិនណាគឺយើងយកបិននឹងចាសហើយយើងនឹងក៏បានទៅវាយលាសអីចឹងទៅលោកក្មួយហាសចាសហើយនៅពេលដែលយើងទៅវាយលាសគឺយើងបានយកលាសទាំងអស់នឹងយកមកប្តូរជាបាយហើយនឹងអង្ករចាសនិយាយទៅគឺខ្ញុំនឹងកំសត់ណាស់ទៅវាយលាសយកមកប្តូរជាបាយហើយនឹងអង្ករហើយលាស២រឺក៏៣កំប៉ុងចឹងទៅប្តូរបានតែអង្ករ១កំប៉ុងរឺក៏៣កំប៉ុងចឹងទៅហាសចាសនិយាយទៅអោយតែបានហូបចាសរស់បានមួយថ្ងៃមួយថ្ងៃចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់ពោលពតនឹងលោកយាយគឺទាន់បានចាយលុយនោះទេមែនដែលទេលោកយាយ???

ខ៖ ចាសដាល់ដែលនៅក្នុងបែកនឹងគឺនៅក្នុងឆ្នាំ ១៩៨១
អីនឹងគឺគេបានចេះចាយលុយហើយតាចាសហើយនៅពេលដែលគេចាយលុយនឹងគឺគេបានចាយលុយតែរបស់វៀតណាមនោះទេចាសដូចថានៅពេលដែលយើងលក់ដូរបានអីចឹងទៅគឺយើងយកទៅប្តូរជាលុយរបស់វៀតណាមអីចឹងទៅហាសចាសនឹងហើយនៅពេលដែលគេទិញអីអីចឹងទៅហើយក៏មានអ្នកខ្លះនឹងគឺគេបានប្តូរជាអង្ករចឹងទៅចាសហើយដូចថាយើងមានត្រីអីចឹងទៅគឺយើងអាចប្តូរយកជាអង្ករចឹងទៅហាសចាសដូចថាយើងនិយាយហើយនៅពេលដែលយើងបានប្តូរយកអង្ករនឹងហើយចាសហើយអ្នកណាដែលគេមានមាសចឹងទៅគឺគេប្តូរយកជាអង្ករចឹងទៅហាសចាគឺគេអ្នកលក់ដូរតាមផ្សារចឹងទៅហាសចាសកាល់នៅក្នុងជំនាន់នឹងគឺបានបែកនៅក្នុងជំនាន់ឆ្នាំ
១៩៨០ជាងអីនឹងគឺគេត្រូវការចាយលុយចឹងហាសហើយពេលនឹងគឺយើងចាយលុយរបស់វៀតណាមចឹងហាសចាស៕

កៈ
ចាសចឹងនៅក្នុងជំនាន់នឹងគឺពួកពោលពតគឺគេចាយលុយវៀតណាមមែនដែលទេលោកយាយ???

ខៈ ចាសនៅក្នុងជំនាន់នឹងគឺគេបានចាយលុយរបស់ជនជាតិវៀតណាម៕

កៈ
បាទហើយចឹងនៅពេលដែលលោកយាយបានបែកពីជំនាន់ពោលពតហើយចឹងសូម្បីតែអីវ៉ាន់តែបន្តិចក៏លោកយាយមិនបានប្រមូលដែលមែនដែលទេលោកយាយ???

ខៈ
ចាសអត់មានទេពីព្រោះអីនឹងគឺខ្ញុំនឹងមិនហ៊ានអីចឹងហាសលោកក្មួយហើយម្យ៉ាងទៀតម្តាយរបស់ខ្ញុំនឹងគាត់បាននិយាយថាទ្រព្យរបស់គេហើយខ្លាចជារបស់គេចឹងទៅគឺគេមកយកវិញចឹងហាសចាសហើយសំរាប់គេនៅពេលដែលគេទៅហើយគេដឹកបានអីវ៉ាន់ជាច្រើនណាស់ហើយសំរាប់ក្រុមគ្រួសាររបស់ខ្ញុំនឹងគឺអត់មានទេចាសហើយសំរាប់ម្តាយរបស់ខ្ញុំនឹងគឺគាត់មិនអោយទៅយករបស់ទ្រព្យរបស់គេទេពីព្រោះអីចឹងវាជារបស់គេហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលលោកយាយបានបែកពីជំនាន់ពោលពតហើយនៅពេលដែលលោកយាយបានរត់តាមផ្លូវនឹងហាសថាតើលោកយាយបានជួបនឹងពួកពោលពតដែលរឺទេលោកយាយ???

ខៈ
ចាសនៅពេលដែលខ្ញុំនឹងបានបែកពីជំនាន់ពោលពតនឹងនៅពេលដែលមកគឺខ្ញុំនឹងមិនបានជួបនោះទេចាសដូចថានៅពេលដែលកងទ័ពរបស់យើងបានអីចឹងគឺវាបានរត់ទៅចឹងហាសចាសហើយពួកពោលពតវាបានរត់ទៅឡើងលើភ្នំអីចឹងហាសចាសនិយាយទៅគឺមិនបានជួបនោះទេនិយាយទៅគឺមានតែទ័ពរបស់ជនជាតិវៀតណាមយើងនឹងនោះទេចាស៕

កៈ
បាទហើយចឹងនៅពេលដែលលោកយាយបានជួបនឹងកងព័ទរបស់វៀតណាមចឹងថាតើគេមានបានធ្វើក្រុមគ្រួសាររបស់លោកយាយដែលរឺទេលោកយាយ???

ខៈ
ចាសនិយាយទៅកងព័ទរបស់វៀតណាមគឺមិនបានធ្វើបាបខ្ញុំនឹងហើយនឹងគ្រួសារខ្ញុំនោះទេចាសកងព័ទរបស់វៀតណាមគឺមិនបានធ្វើបាប់ខ្ញុំនោះទេមានតែដេញអោយយើងនឹងឡើងមកពីក្នុងព្រៃហាសចាសនិយាយទៅគឺខ្ញុំនឹងគឺកំសត់ខ្លាំងណាស់ដូចថានៅពេលដែលខ្ញុំនឹងបានរត់ចាសនិយាយទៅគឺខ្ញុំនឹងបានរត់ចូលទៅក្នុងព្រៃហាសហើយនៅពេលគឺខ្ញុំនឹងបានប៉ោលប្អូនប្អូនរបស់ខ្ញុំនឹងគាត់មានអាយុតែ ៧ឆ្នាំ ហើយនឹង ៨ឆ្នាំ

ប៉ោលផងទៀញផងចុះយើងចុះទៅក្នុងទឹកដើម្បីលុយទឹកហាសចាសហាសហើយពេលនឹងគឺគ្រាប់ប្លោងមកលឺស្វូតែដុងដុងហាសហើយនៅពេលនឹងយើងនឹងចេះតែរត់ទៅហើយបានរត់ចូលទឹកហើយទឹកនឹងវាចេះតែជ្រៅទៅជ្រៅទៅហើយសំរាប់យើងនឹងយើងវាភ័យហាសចាសហើយពេលនឹងយើងបានឡើងមកវិញហើយទំរាំមតែយើងនឹងបានឡើងមកវិញនឹងបានមកដ៏ភ្នំពេញហើយសំរាប់ប្អូនរបស់ខ្ញុំនឹងគឺវាបានគៀកមកហើយយើងទាំងអស់គ្នានឹងគឺគ្មានព្រទ្យសម្បត្តិនោះទេចាសនិយាយៅទៅអោយតែបានរស់តែមួយខ្លួនហើយបានមកចឹងទៅចាសនិយាយទៅគឺខ្ញុំនឹងកំសត់ណាស់អត់មានថានៅពេលដែលយើងបានមកដល់អីចឹងហាយើងទៅយកអីវ៉ាន់នៅភ្នំពេញហាសចាសនិយាយទៅគឺក្រុមគ្រួសាររបស់ខ្ញុំនឹងគឺគញមាននោះទេចាសអោយតែរស់ហើយយើងនឹងសុំតែមួយរស់បានហើយចាស៕

ក៖

បាទហើយនៅពេលដែលលោកយាយបានមកដល់ភ្នំពេញហើយកាល់នឹងបែកពីជំនានពោលពតនឹងហើយគេបានដេញអោយលោកយាយបានមកចឹងហាសលោកយាយហើយនៅពេលដែលគេបានដេញហើយថាតើលោកយាយបានប្រកបមុខរប់អ្វីដែលទៅសំរាប់ចិញ្ចឹមជីវិតរបស់លោកយាយហាសលោកយាយ៕

ខ៖

ចាសកាល់នៅក្នុជំនាន់នឹងគឺខ្ញុំនឹងបានទៅរៀវលាសហើយនៅពេលដែលខ្ញុំននឹងបានរៀវលាសហើយចឹងហើយគេបានហៅខ្ញុំនឹងអោយធ្វើការងារអីចឹងទៅហើយនៅពេលដែលយើងបានធ្វើការងារដូចដល់ម៉ោងរាជរដ្ឋាភិបាលហើយអោយគេនឹងបានជួសជុសសំរាប់ឃ្លាំងអីអីចឹងទៅហាសគឺសំរាប់ដាក់អោយយើងហាសចាសហើយនៅពេលនឹងគឺយើងទាំងអស់នឹងគឺយើរបានដើរធ្វើចឹងហាសចាសហើយនៅពេលដែលយើងបានធ្វើការងារនឹងគឺយើងបានប្រាក់ខែនឹងដូចជាពោតសំលីហើយើនៅពេលដែលយើងនឹងដូចជាថាយើងនឹងគឺកំសត់ណាស់ហើយនៅក្នុងជំនាន់នឹងគឺយើងអត់ទាល់មានលុយសំរបស់ចាសយនោះទេចាសនៅក្នុងជំនាន់យើងបានដីជាជាពោតសំលីហើយពេលនឹងខ្ញុំនឹងក៏បានម្សៅមីហើយនៅពេលដែលយើងបានហើយចឹងទៅគឺយើងយករបស់របបដូចជាអង្ករហើយយើងក៏បានដាក់ទុក្ខសំរាប់មួយខែចឹងទៅហាសចាសហើយនៅក្នុងជំនាំនឹងដូចជាប៉ុន្មាននោះទេចាសគឺប្រាក់ខែរបស់គាត់គឺមានតិចដែកចឹងទៅចាសនៅពេលនឹងប្រសិនជាយើងបានឃើញ២០ដុល្លារហើយនឹង៣០ដុល្លារចាសនិយាយទៅកាល់នៅក្នុងជំនាន់នឹងដូចថាលុយរបស់ជនជាតិវៀតណាមនឹងគឺមានតំម្លៃអីចឹងទៅហាស៕

ក៖

បាទហើយនៅពេលដែលលោកយាយបានលុយនឹងថាតើលុយទាំងអស់នឹងគឺជាលុយរបស់ជនជាតិវៀតណាមរឺក៏លុយរបស់ខ្មែររបស់យើងនឹងហាស???

ខ៖ ចាសនិយាយទៅគឺលុយនឹងគឺជាលុយរបស់ខ្មែរយើងនឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលលោកយាយបានទៅធ្វើការងារអោយគេចឹងក្នុងមួយខែចឹងលោកយាយបានទទួលដូចជាម្សៅមីហើយនឹងអង្ករហើយទាំងអស់នឹងគឺលោកយាយយកគឺដើម្បីផ្គត់ផ្គង់ជីវិតរបស់លោកយាយហើយនឹងក្រុមគ្រួសាររបស់លោកយាយបាទហើយនៅពេលដែលលោកយាយផ្គត់ផ្គង់នឹងនៅក្នុងក្រុមគ្រួសាររបស់លោកយាយមានគ្នាចំនួនប៉ុន្មាននាក់ដែលទៅលោកយាយ???

ខ៖ ចាសនិយាយទៅការផ្គត់ផ្គង់នៅក្នុងក្រុមគ្រួសាររបស់ខ្ញុំនឹងមានគ្នាចំនួន ៨នាក់ចាស៕

ក៖
បាទចឹង៨នាក់មែនដែលទេលោកយាយចឹងបានន័យថាលោកយាយគឺអ្នកផ្គត់ផ្គង់ពួកគាត់ទាំងអស់មានគ្នា៨នាក់មែនដែលទេលោកយាយ???

ខ៖
ចាសនិយាយទៅដូចថាមានប្អូនរបស់ខ្ញុំនឹងខ្លះទៅគាត់បានទៅរៀនលាសអីចឹងហាសហើយក៏មានអ្នកខ្លះទៀតទៅធ្វើការងារអីចឹងទៅចាសដល់ពេលយូរយូរចឹងបានបានជាអង្ករហាសចាសហើយសំរាប់មួយខែនឹងគឺយើងបានអង្ករជាង៥០គីឡូរឺក៏៦០គីឡូរអង្ករចឹងដែលហាសចាសដល់ពេលយូរយូរទៅបាន៨០ជាងចឹងហាសចាសហើយនៅពេលដែលយើងបានអង្ករចឹងទៅបានជាង៥០រឺក៏៦០គីឡូចឹងទៅហើយយើងចេះតែចិញ្ចឹមប្អូនរបស់យើងនឹងទៅរហូតមកបានមានជីវិតនឹងគេចឹងហាសចាសហើយលូវនឹងប្អូនប្អូនរបស់ខ្ញុំនឹងគឺគេបានមានគ្រួសារអីអស់ចឹងទៅចាស៕

ក៖
បាទហើយចឹងសំណួរដែលខ្ញុំនឹងសួរទៅកាន់លោកយាយបន្ថែមទៀតថាតើក្រោយពីមានការបែកពីជំនាន់ពោលពតហើយចឹងហាសលោកយាយហើយលោកយាយបានរស់នៅភ្នំពេញថាតើលោកយាយមានបទពីសោធប៏ដែលសប្បាយសប្បាយអីខ្លះខ្លះដែលរឺទេដែលដូចជាជៀសផុសពីភាពដែលលំបាក់ថាតើលោកយាយមានបទពីសោធប៏ដែលសប្បាយសប្បាយនៅក្នុងជីវិតរបស់លោកយាយដែលរឺទេលោយាយ???

ខ៖
ចាសនិយាយគឺខ្ញុំនឹងមានដែលដូចថ្ងៃណាទៅដែលគេមានបុណ្យទានអីចឹងទៅគឺខ្ញុំនឹងចេះតែសប្បាយអីនឹងគេចឹងទៅហេហេហេដូចជាការសប្បាយជាមួយនឹងបងប្អូនរបស់ខ្ញុំនឹងហើយចៅរបស់ខ្ញុំនឹងចឹងទៅហាសចាសហើយដូចថានៅពេលដែលគេមានបុណ្យទានអីចឹងទៅគឺគេបានមកបបួលហើយនឹងដើរទៅតាមមាត់ទន្លេរអីចឹងទៅហើយនឹងចេះតែតាមគេចឹងទៅហាសហើយសំរាប់ខ្ញុំនឹងក៏បានបបួលចៅហើយនឹងបានទៅដើរលេងនឹងគេនឹងឯងចឹងទៅហាសចាសវាសប្បាយវាគ្រាន់ជាងនៅក្នុងជំនាន់ពោលពតហាសចាសនិយាយទៅគឺសប្បាយមែនទែនហើយសប្បាយរាប់រោយដងពីពួកពោលពតទៀតពីព្រោះអីនឹងនៅក្នុងជំ

នាន់ពោលពតនឹងគឺយើងនឹងមិនបានហូបបានឆ្អែតផងនឹងហាសហើយចុះមកសម័យនេះនៅពេលដែលយើងដើរមួយសេរីហើយយើងកុំទៅមើលងាយគេទៅបានហើយដើរទៅណាមួយសេរីហើយនៅពេលដែលយើងមានលុយគឺយើងអាចហូបបានមួយសេរីហាសនិយាយទៅគឺសប្បាយចិត្តហេហេហេហើយនៅពេលដែលយើងចង់ទៅណាចឹងគឺយើងមានសុវត្តិភាពទាំងអស់ចឹងបានថាយើងបានរស់រានមានជីវិតចឹងហាសនិយាយទៅវាអស្ចារ្យណាស់ហើយវាអស្ចារ្យណាស់ហើយយើងនឹងចេះតែរកចឹងទៅពីព្រោះអីនឹងយើងនៅក្នុងជំនាន់ពោលពតនៅពេលដែលយើងឆ្លងខេត្តនឹងក៏វាមិនបានអោយនឹងបានឆ្លងផងមិនបាច់និយាយខេត្តទេសូម្បីតែភូមិនឹងក៏វាមិនបានអោយយើងនឹងបានឆ្លងទៅដែលហាសចាសហើយសំរាប់ឪពុកហើយនឹងម្តាយនឹងក៏វាមិនបានអោយយើងនឹងបានជួបគ្នាដែលហាសចាសហើយមកនៅក្នុងជំនាន់នេះប្រសិនជាយើងនឹងចង់ដើរទៅណាក៏បានអោយតែយើងនឹងវាមានលុយហាសហេហេហេចឹងណាលោកក្មួយចាសនិយាយទៅអោយតែយើងនឹងមានលុយហាហាហាចាស៕

ក៖

បាទហើយចឹងខ្ញុំនឹងចង់សួរទៅកាន់លោកយាយ១សំណួររឺក៏២សំណួរទៀតចឹងខ្ញុំនឹងចង់សួរសំណួរទៅលោកយាយថានៅពេលដែលលោកយាយបានបែកពីជំនាន់ពោលពតហើយចឹងហាសថាតើលោកយាយមានបទពីសោធន៍ដែលមានភាពសប្បាយសប្បាយគឺលោកយាយមានហើយចឹងទៅចឹងខ្ញុំនឹងចង់សួរលោកយាយពីបច្ចុប្បន្នភាពវិញម្តងហាសលោកយាយថាតើនៅពេលដែលលោកយាយបានបែកពីជំនាន់ពោលពតហើយចឹងថាតើភាពដែលលំបាក់របស់លោកយាយមានជួបបញ្ហាលំបាក់អ្វីខ្លះដែលទៅលោកយាយអាចចែកចាយអោយខ្ញុំនឹងបានស្តាប់បានដែលរឺទេលោកយាយ???

ខ៖

ចាសនិយាយទៅគឺខ្ញុំនឹងជួបដែលចឹងហាសក៏ប៉ុនតែនឹងគឺយើងនឹងបានចិញ្ចឹមចៅចិញ្ចឹមអីនឹងហាសចាសហើយនឹងមានភាពលំបាក់ដូចជាការដើរលក់ដើរដូរអីចឹងទៅហើយសំរាប់យើងនឹងគឺបានតែហូបមួយរស់មួយរស់នោះទេហេហេហេមួយរស់ចាសក៏ប៉ុនតែវាក៏គ្រាន់ជាងហើយនឹងសប្បាយជាងនៅក្នុងជំនាន់ពោលពតដែលចឹងហាសចាសពីព្រោះអីនឹងគឺយើងនឹងមានសេរីភាពចាសនិយាយទៅតាំងពីការហូបចុកហើយនឹងការហើរនិយាយទៅគឺមួយសេរីចឹងហាសចាសហើយក៏គ្មាននាក់មកថាអីអោយយើងចឹងហាសហេហេហេដូចខ្ញុំនឹងបានជំលាបលោកក្មួយចឹងអោយតែយើងនឹងមានលុយយើងទៅដល់ខេត្តណាស្រុកណាក៏បានដែលចឹងហាសហេហេហេចាសនិយាយទៅគឺសំខាន់រឿងលុយតែម្តងហាសហេហេហេអោយតែមានលុយ៕

ក៖

បាទហើយចឹងឪពុកហើយនឹងម្តាយរបស់គាត់សព្វថ្ងៃនឹងថាតើគាត់នៅទីកន្លែងណាវិញដែលទៅលោកយាយ???

ខ៖

ចាសសព្វថ្ងៃនឹងគឺពួកគាត់នឹងគឺបានលេងគ្នាហើយចាសហើយសំរាប់ម្ដាយរបស់គាត់មានប្ដីនឹងទៅរស់នៅខាងស្រុកចម្ការចេកហើយកូនរបស់ខ្ញុំនឹងមានតែមួយនឹងប្រុសនឹងចាសហើយសំរាប់កូនប្រុសរបស់ខ្ញុំនឹងគឺគាត់មានប្រពន្ធនៅខេត្តកំពុងធំហាសចាសហើយបន្ទុកនឹងគឺត្រូវបានធ្លាក់មកលើកខ្ញុំនឹងត្រូវចិញ្ចឹមចៅទាំង៣នាក់នឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងប្រកបមុខរបរដើលលក់នុំអីនឹងចឹងទៅគឺដើម្បីចិញ្ចឹមរបស់ខ្ញុំនឹងហាសចាសតែយ៉ាងណាក៏ដោយធ្វើយ៉ាងគឺអោយយើងនឹងបានសប្បាយសប្បាយចឹងទៅហាសលោកក្មួយហាសចាសអោយតែសប្បាយចិត្តនឹងចិញ្ចឹមចៅរបស់ខ្ញុំនឹងគឺខ្ញុំនឹងចេះតែទៅហើយចាសនិយាយទៅគឺអោយតែបានមួយរស់មួយរស់ចឹងទៅគឺខ្ញុំនឹងមិនជាចង់បានអ្វីនោះទេអោយតែបានមួយរស់មួយរស់ហើយនឹងបានសប្បាយចិត្តទៅវាបានហើយចឹងហាសចាស៕

ក៖

បាទហើយចឹងខ្ញុំនឹងចង់សួរទៅកាន់លោកយាយថាតើរាល់ខែនឹងឪពុកើហយនឹងម្ដាយរបស់គាត់នឹងមានបានផ្ដល់សាច់ប្រាក់អោយទៅកាន់គាត់គឺដើម្បីចិញ្ចឹមជីវិតរបស់គាត់ទាំងអស់គ្នាដែលរឺទេលោកយាយរឺក៏យ៉ាងមិចដែលទៅ???

ខ៖

ចាសសំរាប់រាល់ខែគឺឪពុកហើយនឹងម្ដាយរបស់គេនឹងគឺបានផ្ដល់តែបន្តិចហាសជួនកាលគេមានលុយអីចឹងទៅគេបានផ្ដល់អោយគាត់ទាំងអស់នឹងបាន១០០០០០រចឹងទៅហើយសំរាប់ខែណាដែលបានមួយខែជាងចឹងទៅគឺគេបានផ្ដល់ប្រាក់
១៥០០០០រចេងទៅចាសហើយនិយាយទៅគឺយើងនឹងទោមទៅមិនរួចចឹងហាសចាសពីព្រោះអីចឹងយើងមានច្រើនណាស់សំរាប់ចំណាយដូចជាទឹកហើយនឹងភ្លើងហើយនឹងចៅទៅរៀនប្រចាំថ្ងៃនឹងមានចំនួន៣នាក់ហើយនៅក្នុង១នាក់នឹងគឺចំណាយអស់១០០០០រក្នុងចំនួន៣នាក់នឹងចាសហើយសំរាប់សៀវភៅសិក្សាផងហើយនឹងកាហ្វបចុកអីផងចឹងទៅចាសជួលកាលនឹងមានទៅដល់៧០០០រឺក៏៨០០០រចឹងទៅហើយខ្ញុំនឹងលក់នុំបានតែ១០០០០ជាងនឹងតែយើងធ្វើយ៉ាងមិចចេះតែអោយមួយរស់ចឹងហាសហេហេហេចាសអោយតែមួយរស់ដូចខ្ញុំនឹងបានជំលាបលោកក្មួយចឹងហាសថាវាគ្រាន់បើលជាកាលដែលខ្ញុំនឹងបានរស់នៅក្នុងជំនាន់ពោលពតចឹងហាសហេហេហេនិយាយទៅគឺយើងរស់បានល្អជាងកាល់នៅក្នុងជំនាន់ពោលពតហាសហើយវាក៏វាបានសប្បាយជាងកាល់នៅក្នុងជំនាន់ពោលពតដែលចាសហើយយើងចង់ទៅណាក៏បានហើយយើងចង់ឈប់សំរាប់១ថ្ងៃរឺក៏២ថ្ងៃនឹងក៏បានតាមចិត្តយើងចឹងហាសហើយយើងចេះតែដើរទៅនេះទៅនោះចឹងទៅគឺយើងមិនចាំបាច់ភ័យហើយយើងនឹងក៏មានភាពសប្បាយចិត្តដែលចឹងហាសចាសហាហាហាចាស៕

ក៖

បាទហើយចឹងថ្ងៃនឹងសំរាប់ខ្ញុំនឹងគឺគ្មានអ្វីច្រើនសំរាប់លោកយាយនោះទេក៏ប៉ុនតែខ្ញុំពិតជាសប្បាយចិត្តមែនទែនដែលបានជជែកលេងជាមួយនឹងលោកយាយហើយនឹងបានពិភាក្សា

ជាមួយនឹងលោកយាយផងដែលហើយនឹងបានផ្តល់ការសំភាសន៍អោយខ្ញុំនឹងបាទចឹងហាសលោកយាយចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកយាយ១ទៀតថាតើលោកយាយមានអ្វីនឹងផ្តែលផ្តាំទៅកាន់កូនចៅរបស់លោកយាយដែលរឺទេនៅពេលដែលគេបានលឺសំលេងរបស់លោកយាយហើយនៅពេលដែលគាត់បានលឺចឹងអោយគាត់បានលឺសំលេងរបស់លោកយាយអោយពួកកាត់ចេះផ្តល់កំលាំងចិត្តទៅកាន់លោកយាយរឺក៏ចេះគោរពលោកយាយដែលជាម្តាយរបស់គាត់ដែលថាតើលោកយាយមានអ្វីនឹងផ្តែលផ្តាំទៅកាន់គាត់ដែលរឺទេលោកយាយ???

ខ៖

ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងចង់ផ្តែលផ្តាំទៅកាន់បងប្អូនហើយនឹងកូនចៅទាំងអស់របស់ខ្ញុំនឹងចឹងហាសអោយមានចិត្តតានៅពេលដែលយើងខំពុះពារហើយនឹងរកស៊ីនឹងដើម្បីចិញ្ចឹមជីវិតហាសហើយយើងទាំងអស់គ្នានឹងសូមកុំខ្ជិលច្រអូសចាសហើយកាល់ណាដែលស្រុករបស់យើងនឹងបានបិននឹងហើយចឹងហាសហើយយើងស្រែកថាក្រហើយយើងនឹងមិនបានទៅរកស៊ីអីចឹងហើយយើងខំប្រឹងនឹងរកក៏វាមិនបានដែលចឹងហាសលោកក្មួយហាសហើយនៅពេលដែលបានលុយបន្តិចបន្តួចចឹងទៅក៏ទៅលេងល្បែងអស់ហើយយើងនឹងបានអីហូបល្បែងហេហេហេតែប្រសិនជាយើងនឹងខំលើកស្ទួយជីវភាពរបស់យើងហើយនឹងខំរកអីចឹងទៅហាសហើយនឹងខំប្រឹងធ្វើចឹងហើយនឹងតស៊ូរចឹងទៅចាសធ្វើដូចខ្ញុំនឹងទៅទោះខ្ញុំនឹងវាមានភាពលំបាក់យ៉ាងណាក៏ដោយហើយគឺខ្ញុំនឹងគឺតស៊ូរស៊ូរស៊ូរស៊ូរស៊ូរនៅក្នុងជីវិតហើយខ្ញុំនឹងគឺដើរលក់នុំណាលោកយាយចាសរាល់ថ្ងៃនឹងហាសហើយនៅពេលដែលខ្ញុំនឹងបានលឺគេណាអីនឹងបានស្លាប់អីចឹងទៅគឺខ្ញុំនឹងចេះតែតស៊ូរនៅក្នុងជីវិតរបស់ខ្ញុំនឹងហាសចាសគឺតស៊ូរនៅក្នុងជីវិតណាលោកក្មួយហាសចាសហើយសំរាប់ខ្ញុំនឹងនៅពេលដែលខ្ញុំនឹងបានដើរតាមផ្លូវនឹងគឺខ្ញុំនឹងតែតែងទុនទិញធម្មចឹងហាសលោកក្មួយហេហេហេនិយាយទៅគឺខ្ញុំនឹងសូមសើចតិចចុះហាសចាសចាសនៅពេលដែលខ្ញុំនឹងបានដើរតាមផ្លូវនឹងគឺខ្ញុំនឹងតែតែងទុនទិញធម្មចឹងហាសចាសហើយប្រសិនជាស្លាប់នឹងនឹងគឺខ្ញុំនឹងនិយាយថថាហ៊ុមជីវិតរបស់ខ្ញុំអើយគឺខ្ញុំនឹងមិនបានដឹងថាថ្ងៃណាទេដូចគេនោះទេចាសនិយាយទៅនៅពេលដែលខ្ញុំនឹងបានគិតចឹងគឺយើងទាំងអស់គ្នានឹងយើងមើលមិនឃើញនោះទេចាសនិយាយទៅនៅយើងទាំងអស់គ្នានឹងយើងមើលមិនឃើញនោះទេមែនដែលទេមីអូនចាសគឺយើងទាំងអស់គ្នានឹងយើងមើលមិនឃើញនោះទេមិនថាចាស់ហើយនឹងមិនថាក្មេងនោះទេលើកលេងតែព្រះអនុននោះទេដែលគាត់គឺជាព្រះហើយមិនចេះស្លាប់នោះចឹងហាសហេហេហេចាសគឺយើងទាំងអស់គ្នានឹងយើងមើលមិនឃើញនោះទេទេមិនថាចាស់ហើយនឹងមិនថាក្មេងនោះទេហើយសំរាប់រាល់ថ្ងៃនឹងគឺខ្ញុំនឹងបាននិយាយថានៅពេលដែលខ្ញុំនឹងអត់ឈឺចឹងទៅគឺខ្ញុំនឹងចេះតែមានទឹកចិត្តសំរាប់នឹងរកស៊ីចឹងទៅគឺសំរាប់តែចិញ្ចឹមចៅរបស់ខ្ញុំនឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងឈឺគឺខ្ញុំនឹងមានអារម្មណ៍ថាពីបាក់ចិត្តខ្លាំងណាស់ចាសហើយនៅពេលដែលខ្ញុំនឹងឈឺគឺខ្ញុំនឹងមានអារម្មណ៍ថាពីបាក់ចិត្តខ្លាំងដូចថា២ថ្ងៃមុននឹងខ្ញុំនឹងបានឈឺចឹងហើយខ្ញុំនឹងបានវល់ហើយខ្ញុំនឹងបានតោងគ្រែចឹងហាសហើយសំរាប់ចៅរបស់ខ្ញុំនឹងគឺខ្ញុំនឹងបា

ននិយាយថៅអើយកោតខ្យលអោយបន្តិចមកយាយរល់មុនខ្លាំងណាស់ហើយឈឺតែងក
ណ្ដាលអព្រាត់ហើយខ្ញុំនឹងក៏បានឈប់សំរាក់២ថ្ងៃចឹងទៅហាសចាសហាហាហា៕

កៈ
បាទហើយចឹងអរគុណច្រើនលោកយាយចឹងសំរាប់លោកយាយមានអ្វីនឹងបន្ថែមទៀតនៅ
ពេលដែលលោកយាយចង់ផ្ដែលផ្ដាំទៅថៅលោកយាយទៀតចឹងហាសអោយគាត់ខំប្រឹងអ្វី
បន្ថែមទៀតដែលរឺទេលោកយាយ???

ខៈ
ចាសសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងខំប្រឹងប្រដៅថៅរបស់ខ្ញុំនឹងអោយពួកគាត់បានដឹងថាយាយនឹងគឺ
ខិតខំដើរទូរលក់នុំហើយនឹងបានលុយមកគឺសំរាប់អោយថៅនឹងបានទៅរៀនសូត្រហើយនឹ
ងអោយថៅបានខំប្រឹងនឹងបានរៀនសូត្រនឹងហាលោកក្មួយហាសដើម្បីមិចគឺដើម្បីទៅថ្ងៃ
ខាងមុខទៀតគឺកុំអោយពិបាក់ដូចជាយាយចឹងហាសចាសទូរនុំដើរលក់ចឹងទៅចាសហើយ
នៅពេលដែលយើងមានចំណេះដឹងចឹងទៅដូចលោកក្មួយចឹងហាសហើយប្រសិនជាយើង
គ្មានចំណេះនោះទេនិយាយទៅគឺពិបាក់ហើយហើយប្រសិនជាចេះលក់នុំដូចខ្ញុំទៅវាគ្រាន់
ហើយហើយប្រសិនជាមិនចេះលក់នុំធ្វើយ៉ាងមិចទៅនិយាយទៅគឺវាពីបាក់ចាសចឹងបានខ្ញុំ
នឹងប្រដៅថៅថៅរបស់ខ្ញុំនឹងចឹងហាសអោយចេះតស៊ូរនៅក្នុងជីវិតចាសនិយាយទៅគឺខ្ញុំនឹង
កំសត់ខ្លាំងណាស់ចាសនៅពេលដែលខ្ញុំនឹងបានកើតមកគឺខ្ញុំនឹងបានចិញ្ចឹមបងហើយចិញ្ចឹ
មប្អូនចាសនិយាយទៅចិញ្ចឹមក្មួយដែលគេនឹងកំព្រាទៀតចាសនិយាយទៅថាមួយឆាតជីវិត
របស់ខ្ញុំនឹងគឺខ្ញុំនឹងឆ្អែតតែម្ដងគឺខ្ញុំនឹងឆ្អែតនៅជីវិតរបស់ខ្ញុំតែនឹងយើងនិយាយពីធម្មរបស
ព្រះវាជាកម្មហើយនឹងគឺជាអកុសលផលបុណ្យរបស់យើងចឹងហាសចាសលោកក្មួយតែយើ
ងកំតួចចិត្តយើងត្រូវតែស៊ូរស៊ូរស៊ូរនៅក្នុងជីវិតរបស់យើងចាស៕

កៈ
បាទលោកយាយហើយចឹងថ្ងៃនឹងខ្ញុំសប្បាយចិត្តមែនទែនលោកយាយចឹងអ្វីដែលលោក
យាយនឹងផ្ដែលផ្ដាំទៅកាន់កូនថៅរបស់លោកយាយជាពិសេសថៅថៅដែលគាត់បានរស់
នៅជាមួយនឹងលោកយាយសូមអោយគាត់ទាំងអស់គ្នានឹងអោយគាត់នឹងខំរៀនហើយនឹង
ដើម្បីអាចអោយគាត់បានអភិវឌ្ឍរឺក៏អោយគាត់មានជីវិភាពនឹងបានល្អប្រសើឡើងវិញចឹង
ហើយនឹងសំរាបថ្ងៃអនាគតរបស់ពួកគាត់បាទហើយចឹងខ្ញុំនឹងសង្ឃឹមនៅពេលដែលពួកគា
ត់បានលឺសំលេងរបស់លោកយាយហើយចឹងសូមអោយគាត់ខិតខំប្រឹងប្រែងហើយចេះស្រ
លាញ់លោកយាយហើយនឹងចេះគោរពលោកយាយហើយនឹងដើម្បីអោយពួកគាត់បានទទួ
លនៅអ្វីដែលល្អល្អដែលជាបទពីសោធន៍ដែលលោកយាយបាននៅក្នុងជំនាន់ពោលពតនឹ
ងហាសកុំអោយគាត់ចេះតែមានភាពស្រណុកស្រួលពេកបាទ៕

ខៈ
ចាសសំរាប់ក្មេងលូវនឹងគឺមិនដឹងថាស្រណុកស្រួលនឹងវាយ៉ាងមិចទេហើយបាយជូនកាល់
ចឹងហាសនៅពេលដែលគេបានចាយបាយអោយយើងចឹងយើងមិនទាន់បានហូបផងនឹងគឺ

បានលួចរបស់យើងយកទៅបាត់ចឹងហើយខ្ញុំនឹងគឺសុទ្ធចិត្តអត់មានចឹងហាសចាសប្រវត្តពីជំនាន់ពោលពតហាសជួលកាល់នៅពេលដែលគេបានចាយបាយមួយចឹងហើយនៅពេលខ្លះចឹងទៅក្នុងមួយថ្ងៃនឹងគឺចែកបានតែពតមួយនោះទេក្នុងមួយថ្ងៃចាសហើយប្រសិនជាក្មួយថាតើក្មួយហូបបានឆ្អែតដែលរឺក្មួយចាសនិយាយទៅគឺហូបមិនបានឆ្អែតនោះទេចាសមួយថ្ងៃមួយថ្ងៃហាសហើយសំរាប់ពេលល្ងាចនឹងគឺយើងគ្មានបាយនោះទេគឺគេបានចែកបានតែពោតមួយក្នុងមួយថ្ងៃហើយមានពេលខ្លះនឹងគឺគេបានលួចរបស់យើងចឹងទៅគឺយើងអត់មានអ្វីនឹងហូបនោះទេចាសនិយាយទៅគឺខ្ញុំនឹងសុទ្ធចិត្តចឹងហាសហើយខ្ញុំសុខចិត្តដើរជីកឬឈើអីចឹងទៅគឺយើងចេះតែហូបទៅហាសចាសហើយនៅពេលដែលយើងបានយកឬឈើនឹងបានស្ងោរហូបចឹងទៅគឺយើងហូបហើយគឺយើងរមោសមាត់តែធ្វើយ៉ាងមិចចេះតែហូបទៅគឺដើម្បីបំពេញក្រពេះរបស់យើងចឹងហាសហើយយើងធ្វើការងារអោយគេចាសហើយនៅពេលដែលយើងអត់មានអីហូបយើងមិនហ៊ានតវ៉ានឹងគេទេចាស៕

ក៖
បាទហើយចឹងសំរាប់ថ្ងៃនឹងគឺខ្ញុំនឹងអត់អ្វីច្រើននោះទេលោកយាយចឹងខ្ញុំនឹងបញ្ចប់ជាមួយនឹងលោកយាយតែបិននឹងអរគុណច្រើនមែនទែនលោកយាយដែលបានផ្តល់ការសំភាសន៍អោយក្មួយចឹងហាសលោកយាយ៕

ខ៖
ចាសអរគុណដែលលោកក្មួយហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមានអារម្មណ៍ថាសប្បាយណាស់ដែលបានក្មួយមកសំភាសន៍ខ្ញុំហើយប្រសិនជាខ្ញុំនឹងនិយាយពីរឿងកាល់នៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំមានអារម្មណ៍ចុកចាប់ខ្លាំងណាស់ចាសចាសគឺខ្ញុំមានអារម្មណ៍ចុកចាប់ខ្លាំងណាស់ចុកចាប់ខ្លាំងណាស់ដល់ពេលខ្លះនឹងគឺខ្ញុំបានខ្លៀនអាគេហៅថាក្រៀបបាយហាសដែលវាប្រះប្រះហាសហើយខ្ញុំនឹងបានគិតនៅក្នុងចិត្តប្រសិនជាខ្ញុំនឹងបានតែមួយដុំនឹងប្រហែលជាហូបអោយអស់តែម្តងហាសចាសបើលគេមិនអោយយើងនឹងបានហូបផងនឹងចាសហើយនៅពេលដែលគេជិតបែកនេះទេគឺគេបានធ្វើជានុំបញ្ចុកហើយនឹងធ្វើជាក្រៀបបាយទាំងអស់នឹងគឺដើម្បីសំលាប់យើងចោលចាសហើយនៅពេលដែលយើងបានហូបនៅក្នុងនឹងគឺពួកវានឹងសំលាប់យើងចោលទាំងអស់ចាសនិយាយទៅគឺគេមានពីធីជុបលៀងមានដូចជានុំបញ្ចុកហើយនឹងក្រៀបបាយចាសហើយនិយាយទៅគឺហូបហ៊ាទាំងអស់តែសំរាប់គំរោងរបស់ពួកវានឹងសំលាប់យើងចោលចឹងហាសតែគ្មាននាក់ណាដែលហ៊ានហូបដែលចឹងហាសលោកក្មួយពីព្រោះអីគេបានដឹងពីគំរោងនឹងគឺគ្មាននាក់ដែលហូបនឹងនោះទេចាសហើយគេទាំងអស់នឹងគឺគេគិតតែរត់ហើយនឹងយកតែប្រាស់អាយុរៀងរៀងខ្លួនចឹងហាសចាសហើយបានបានមកដល់ភ្នំពេញចឹងទៅចាស៕

ក៖
បាទចឹងអត់អីទេលោកយាយចឹងថ្ងៃនឹងក្មួយមានតែប៉ុននឹងហើយសំរាប់ក្មួយអរគុណម្តងទៀតសំរាប់ការផ្តល់ការសំភាសន៍អោយក្មួយបានដឹងពីប្រវត្តរបស់លោកយាយកាល់លោក

យាយនៅក្នុងជំនាន់ពោលពតចឹងចឹងថ្ងៃនឹងក្មួយមានតែប៉ុននឹងចឹងខ្ញុំនឹងជំរាបលាលោក
យាយម្តងទៀតហាសបាទចឹងអរគុណច្រើនលោកយាយ៕